ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១១ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២00៧ | តម្លៃ ១.៥00៛

## ប្រទេសកម្ពុជា: កំណើនសេដ្ឋកិច្ច និងលទ្ធផលតាមវិស័យក្នុងឆ្នាំ ២00៦

ភឹម រ៉ុនស៊ីណារិទ្ធិ ពិភាក្សាលើការវាយតំលៃក្នុងគណនីជាតិឆ្នាំ២00៦ ដោយវិទ្យាស្ថានជាតិស្ថិតិ បកស្រាយលើតួលេខសំខាន់ៗនៃការវាយតំលៃនេះ និងផ្តល់មតិលើបញ្ហាមួយចំនួនដែលផុសឡើង ។*

អត្ថបទនេះ ធ្វើការពិភាក្សាពីការវាយតំលៃក្នុងគណនីជាតិ កសាងដោយ វិទ្យាស្ថានជាតិស្ថិតិ (NIS) សំរាប់ឆ្នាំ២00៦ ដែលផ្សាយចេញនៅខែឧសភា ឆ្នាំ២00៧ ។ អត្ថបទ មានបកស្រាយពីតួលេខសំខាន់ៗនៃការវាយតំលៃនេះ និងផ្តល់មតិលើបញ្ហាមួយចំនួនដែលផុសឡើង ដូចជា ចំណងតភ្ជាប់អនុវិស័យសំខាន់ៗ ទៅនឹងផ្នែកដទៃទៀតនៃសេដ្ឋកិច្ច និងការកែសំរួលកំពុងអនុវត្តលើគណនីជាតិ ។


កសិករកំពុងបាចជីក្នុងស្រែនៅខេត្តតាកែវ ឆ្នាំ២00៦

### កំណើន ផសស ពិតសរុប

សេដ្ឋកិច្ចប្រទេសកម្ពុជាបន្តមានដំនើរការយ៉ាងល្អក្នុងឆ្នាំ២00៦ ។ ផសស ពិត កើនឡើង ១0,៦% (២00៦) ដូច្នេះគឺវាមានកំនើនជាលេខពីរខ្ទង់ បានបីឆ្នាំជាប់ៗគ្នាហើយ ។ ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២00៥ (១៣,៦%) វាថយចុះកំណើនដោយសារវិស័យកសិកម្មបានរីកលូតលាស់យឺតជាងមុន ដូចមានបង្ហាញក្នុងក្រាហ្វិក១ និងតារាង១។ នៅឆ្នាំ២00៦ ផសស គិតក្នុងមនុស្សម្នាក់ កើនដល់ ១,៧១៨ លានរៀល (៤១៩ ដុល្លារ) រឺកើន ៨,២% ធៀបនឹងឆ្នាំ ២00៥ ។ សន្ទុះកំនើនភាគច្រើនបានមកពីវិស័យឧស្សាហកម្មដែលមានកំនើនយ៉ាងច្រើនក្នុងផ្នែកកាត់ដេរ សាងសង់ និងពីវិស័យសេវាកម្មផងដែរដែលមានកំនើនគួរកត់សំគាល់ ក្នុងផ្នែកទេសចរណ៍ អចលនទ្រព្យ សេវាកម្មជំនួញ និងសេវាកម្មផ្សេងៗទៀត ។ ស្របតាមលំនាំធម្មតា គេតែងពិនិត្យឃើញជាញឹកញាប់នៅប្រទេសកម្ពុជាដែលមានឆ្នាំខ្លះល្អ ឆ្នាំខ្លះមិនល្អ វិស័យកសិកម្មបានធ្លាក់កំណើនគួរកត់សំគាល់

ក្រាហ្វិក១: កំណើន ផសស (១៩៩៤-២00៦)




* ភឹម រ៉ុនស៊ីណារិទ្ធិ អ្នកស្រាវជ្រាវនៅ វបសអ ។ អត្ថបទនេះ ផ្អែកលើឯកសារវាយតំលៃ គណនីជាតិឆ្នាំ២00៦ ដោយវិទ្យាស្ថានជាតិស្ថិតិ ដែលចេញផ្សាយនៅខែឧសភា ២00៧ ។

## មាតិកា

ប្រទេសកម្ពុជា: កំណើនសេដ្ឋកិច្ច និងលទ្ធផលតាមវិស័យក្នុងឆ្នាំ២00៦ ....... ១
តើគ្រួសារស្ត្រីមេគ្រួនៅជនបទទាំងអស់សុទ្ធតែក្រីក្រយ៉ាងណា ? ....... ៥
ការស្វែងយល់ពីតួនាទីមូលធនសង្គម នៅពេលមានទឹកជំនន់
និងគ្រោះរាំងស្ងួត ....... ៩
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ....... ១៣
— ស្ថានភាពក្នុងប្រទេស ....... ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ....... ១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ....... ២0

*តារាង ១. ផសស ពិត និង កំនើនតាមផ្នែក*

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 |
|---|---|---|---|---|---|---|---|
| ផសស ពិត (ពាន់លានរៀល) | 14,083 | 15,215 | 16,210 | 17,589 | 19,351 | 21,956 | 24,334 |
| ផសស ពិត ក្នុងមនុស្សម្នាក់ (ពាន់រៀល) | 1111 | 1180 | 1237 | 1320 | 1428 | 1588 | 1718 |
| កំនើនពិត ធៀបនឹងឆ្នាំមុន (%) | | | | | | | |
| កសិកម្ម | -0.4 | 3.6 | -2.5 | 10.5 | -0.9 | 15.7 | 5.5 |
| ឧស្សាហកម្ម | 31.2 | 11.2 | 17.1 | 12 | 16.6 | 12.7 | 18.3 |
| សេវាកម្ម | 8.9 | 10.8 | 7.6 | 5.9 | 13.3 | 12.7 | 10.3 |
| ពន្ធលើផលិតផល ដកឧបត្ថម្ភធន | 4.5 | 2.5 | 12.6 | 0.6 | 21.2 | 11.7 | 7.6 |
| ផសស | 8.8 | 8 | 6.5 | 8.5 | 10 | 13.5 | 10.8 |
| ផសសក្នុងមនុស្សម្នាក់ | 7 | 6.3 | 4.8 | 6.7 | 8.2 | 11.2 | 8.2 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

នៅឆ្នាំ២០០៦ បើធៀបនឹងឆ្នាំ២០០៥ ។ ប៉ុន្តែវិស័យនេះ នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅតាមទីជនបទ ដោយប្រជាជនភាគច្រើន នៅតែពឹងផ្អែកលើដំណាំស្រូវ ដើម្បីទ្រទ្រង់ជីវិត ។

## កសិកម្ម

វិស័យកសិកម្មនៅកម្ពុជារួមចំនែក ២៨% នៃ ផសស រឺ ១,៦% នៅក្នុងកំនើន ផសស សរុប (១០,៦%) និងផ្តល់ការងារអោយ ៥៧,៤% នៃកំលាំងពលកម្មសរុប នៅឆ្នាំ២០០៦ (តារាង២) ។ កសិកម្មរួមបញ្ចូល ៤ អនុវិស័យគឺ ការដាំដុះ ការចិញ្ចឹមសត្វ ជលផល និងព្រៃឈើ ។ នៅឆ្នាំ២០០៦ តំលៃបន្ថែមដុលពិតនៃវិស័យនេះ កើន ៥,៥% ធៀបនឹងកំនើន ១៥,៧% នៅឆ្នាំ២០០៥ ដោយសារផលដំណាំ (សមាសភាគសំខាន់នៃវិស័យនេះ) បានរីកលូតលាត់ យឺតជាងឆ្នាំមុន ពីព្រោះមានទឹកជំនន់ ការរាំងស្ងួត ជំងឺ រឺ សត្វល្អិតបំផ្លាញដំណាំ នៅតាមបណ្តាខេត្តមួយចំនួន ។[1] ជាទូទៅ អត្រាកំនើនអនុវិស័យដាំដុះ ប្រែប្រួលជាខ្លាំង (ឡើងដល់កំពូល និងធ្លាក់ដល់បាត) ដែលឆ្លុះបញ្ចាំងពីការពឹងផ្អែកយ៉ាងខ្លាំងលើទឹកភ្លៀង និងការងាយរងគ្រោះដោយកត្តាធាតុអាកាសមិនអំណោយផល ។

*តារាង ២. លទ្ធផលនៃវិស័យកសិកម្ម (ឆ្នាំ២០០៥-២០០៦) គិតជា %*

| | អត្រាកំនើនពិត | | ចំណែកក្នុង ផសស | | ការចូលរួមក្នុងកំនើន ផសស | |
|---|---|---|---|---|---|---|
| | 2005 | 2006 | 2005 | 2006 | 2005 | 2006 |
| កសិកម្ម | **15.7** | **5.5** | **29.5** | **28.1** | **4.5** | **1.6** |
| ដំណាំ | 27.6 | 5.3 | 15 | 14.3 | 3.7 | 0.8 |
| សត្វចិញ្ចឹម រួមទាំង បក្សី | 5.6 | 8.2 | 4.5 | 4.4 | 0.3 | 0.4 |
| ជលផល | 5.6 | 3.8 | 7.8 | 7.3 | 0.5 | 0.3 |
| ព្រៃឈើ និង ការកាប់ឈើ | 5.1 | 7 | 2.2 | 2.1 | 0.1 | 0.2 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

ទន្ទឹមគ្នានេះ ការចិញ្ចឹមសត្វ នេសាទ និងព្រៃឈើ បានកើនឡើងគួរអោយកត់សំគាល់ ប៉ុន្តែបូកបញ្ចូលគ្នាមក មានចំនែកក្នុងកំនើន ផសស តិចជាង ១% គឺប្រហែលគ្នានឹងការដាំដុះដែរ ។ ផលិតកម្មសត្វចិញ្ចឹម និងបសុបក្សី បន្តជួបឧបសគ្គនៃជំងឺឆ្លង ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការផ្ទុះជំងឺផ្តាសាយបក្សី មានដល់ ៦លើក នៅឆ្នាំ២០០៦ ធៀបនឹងពីរលើក ប៉ុណ្ណោះនៅឆ្នាំ២០០៥ ។ វាបានបណ្តាលអោយបសុបក្សី ៧៧៦៧ក្បាលស្លាប់ ហើយបក្សី ១១១៣ក្បាលទៀត ត្រូវបានបំផ្លាញចោល ។ ក្នុងអនុវិស័យជលផល វារីវប្បកម្មខ្នាតតូច នឹងតាមគ្រួសារ បានកើនឡើងពិសេសក្នុងរយៈពេល ៤ឆ្នាំចុងក្រោយនេះ ។

តំលៃបន្ថែមក្នុងអនុវិស័យព្រៃឈើ អាចប៉ាន់ស្មានទាបពេក ដោយសារមានការកាប់ឈើខុសច្បាប់ និងការកំនត់ទាបពេកនូវតួលេខតំលៃពិតនៃផលិតផលមិនមែនឈើហ៊ុប ។ ឧទាហរណ៍ ប្រជាជនយ៉ាងច្រើនមានជីវភាពក្រីក្រ និងត្រូវពឹងផ្អែកលើព្រៃឈើ ទាំងសំរាប់ធ្វើអុសដុត និងសំរាប់ប្រមូលយកផលិតផលមិនមែនឈើហ៊ុប ដើម្បីបង្កើតចំនូល និងបង្កើនការហូបចុក ។ សំពាធសហគមន៏ សង្គមក្នុងទំរង់ជាការប្រមូលយកអុស កសិកម្មផ្លាស់ទី និងការកែប្រែដីជាអចិន្ត្រៃយ៏ ក៏ជាមូលហេតុសំខាន់នៃបាត់បង់ និងខូចគុណភាព្រៃឈើដែរ ។ ការសិក្សារបស់ វបសអ-CDRI បង្ហាញថា អភិបាលកិច្ចធនធានធម្មជាតិ ជាបញ្ហាសំខាន់បំផុត[2] និងត្រូវគ្រប់គ្រងឱ្យមានចិរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ ។

## វិស័យឧស្សាហកម្ម

ឧស្សាហកម្មចូលរួមចំនែក ២៩% ក្នុង ផសស និងប្រើប្រាស់ប្រហែល ១៤,៥% នៃកំលាំងពលកម្មសរុបនៅឆ្នាំ២០០៦ ។ វិស័យនេះរួមចំនែក ៤,៩% ដល់ កំនើន ផសស ធៀបនឹង ៣,៤% នៅឆ្នាំ២០០៥ (តារាង៣) ដោយសារជាសំខាន់ កំនើនខ្ពស់ជាងមុននៃផលិតកម្ម ដែលនាំមុខដោយឧស្សាហកម្មកាត់ដេរ និងការបន្តរីកដុះដាលសកម្មភាពសាងសង់ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ។

វាយនភ័ណ្ឌ និងផលិតកម្មសំលៀកបំពាក់ ជាកត្តាចំបងជួយទ្រទ្រង់វិស័យឧស្សាហកម្ម ក៏ដូចជាសេដ្ឋកិច្ចទាំងមូល ។ វាបានរីកដុះដាលយ៉ាងលឿន ចាប់ពីចុងទសវត្សរ៏១៩៩០ ដោយសារមានលក្ខខណ្ឌពាណិជ្ជកម្មអំណោយផលល្អនៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌចំរុះ (Multi-Fibre Agreement: MFA) ។ បន្ទាប់ពីកិច្ចព្រមព្រៀងបានបញ្ចប់នៅថ្ងៃ១ មករា ២០០៥ អ្នកខ្លះបានទាយទុកថា សេដ្ឋកិច្ចកម្ពុជាអាចត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ប៉ុន្តែតួលេខចុងក្រោយ បានបដិសេធការប៉ាន់ស្មានទាំងអស់

*តារាង ៣. លទ្ធផលវិស័យឧស្សាហកម្មក្នុងឆ្នាំ២០០៥-២០០៦ (គិតជាភាគរយ)*

| | អត្រាកំនើនពិត | | ចំនែក ក្នុង ផសស | | ការរួមចំនែក ក្នុងកំនើន ផសស | |
|---|---|---|---|---|---|---|
| | 2005 | 2006 | 2005 | 2006 | 2005 | 2006 |
| ឧស្សាហកម្ម | **12.7** | **18.3** | **26.9** | **28.7** | **3.4** | **4.9** |
| រ៉ែ | 26.3 | 15.9 | 0.4 | 0.4 | 0.1 | 0.1 |
| ផលិតកម្ម | 9.7 | 17.4 | 19.6 | 20.8 | 2 | 3.4 |
| អគ្គិសនី ឧស្ម័ន និង ទឹក | 12.5 | 31.3 | 0.5 | 0.6 | 0.1 | 0.1 |
| សំណង់ | 22.1 | 20 | 6.4 | 6.9 | 1.3 | 1.3 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

នោះ ។ ការនាំចេញសំលៀកបំពាក់ពីកម្ពុជា ក្រោយពេលចប់ MFA មិនទាន់មានការប៉ះពាល់អ្វីពីប្រទេសចិន ដែលជាមហាយក្សខាងវាយនភ័ណ្ឌ ដូចការទស្សន៍ទាយនោះទេ ពីព្រោះសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បានដាក់កំហិតបន្ថែមលើសំលៀកបំពាក់ចិន នៅខែឧសភា ២០០៥ ។ ប៉ុន្តែ វិធានការជួយគាំពារទាំងនេះនឹងផុតកំនត់ នៅឆ្នាំ២០០៨ ហើយវាអាចបង្កជាបញ្ហាដល់ប្រទេសកម្ពុជាយើង ។

អនុវិស័យសាងសង់បានលូតលាស់កាន់តែខ្លាំងក្នុងច្រើនឆ្នាំកន្លងមកនេះ ។ ការរីកដុះដាលសំនង់បណ្ដាលមកពីកត្តាសំខាន់៧បី គឺៈ ស្ថិរភាពសេដ្ឋកិច្ច ដំណើរការសេដ្ឋកិច្ចរឹងមាំ និងជំនួយជាបន្តពីសហគមន៍អន្តរជាតិសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ។ ការសាងសង់គឺមាន ១/៣ ជាសំណង់សាធារណៈ ដូចជាហេដ្ឋារចនាសម្ព័ន្ធជាដើម និង ២/៣ ជាសំណង់ឯកជន ដូចជា ការសាងសង់និងពង្រីករោងចក្រ សណ្ឋាគារ និងផ្ទះ ជាដើម ។ ប៉ុន្តែ មានការបារម្ភពីការវិនិយោគច្រើនលើសលប់លើសំនង់ផ្ទះនៅរាជធានីភ្នំពេញ ដែលមានការសាងសង់ដល់ ៨.០០០ ទៅ ១០.០០០ផ្ទះល្វែងក្នុងមួយឆ្នាំ។ ។

អនុវិស័យផ្សេងៗទៀតរួមមាន រ៉ែ អគ្គិសនី ឧស្ម័ន និងទឹក មានកំនើនវិជ្ជមានធៀបនឹងឆ្នាំមុន ប៉ុន្តែ ការរួមចំណែកដល់ការរីកលូតលាស់វិស័យឧស្សាហកម្ម និងកំនើនជារួមនៃ ផសស នៅតែតិចតួចនៅឡើយ ។ ប៉ុន្តែខាងរ៉ែមានសក្ដានុពលច្រើនណាស់ ។ ការស្រាវជ្រាវពីដី និងរ៉ែ បានបង្ហាញថាប្រទេសកម្ពុជាមានរ៉ែជាច្រើន ដូចជា បូកស៊ីត រ៉ែត្បូង ប្រេងកាត រ៉ែលោហៈ និងមិនមែនលោហៈ និងសំភារៈបានពីកន្លែងជីកយកថ្ម ។ ដូចគ្នាដែរ ការផ្គត់ផ្គង់អគ្គិសនីបានល្អប្រសើរឡើងនៅតាមទីក្រុង ប៉ុន្តែប្រជាពលរដ្ឋនៅតែជួបការផ្ដាច់ចរន្តអគ្គិសនីផ្លាស់វេនគ្នាក្នុងរដូវក្ដៅ នៅខែមេសា និងខែឧសភា ។ អគ្គិសនីមានតំលៃខ្ពស់បានប៉ះពាល់ដល់គ្រប់វិស័យផលិតកម្ម និងបង្កឧបសគ្គដល់វិនិយោគខាងឧស្សាហកម្ម និងកំលាំងប្រកួតប្រជែង។

## វិស័យសេវាកម្ម

វិស័យសេវាកម្មបានរួមចំនែក ៣៨,២% នៃ ផសស និងផ្ដល់ការងារអោយ ២៨,១% នៃកំលាំងពលកម្មសរុប ។ វិស័យនេះ កើនបាន ១០,៣% នៅឆ្នាំ២០០៦ ធៀបនឹងកំនើន ១២,៧% នៅឆ្នាំ២០០៥ (តារាង ៤) ។ គ្រប់អនុវិស័យបានចូលរួមដល់កំនើននេះ ប៉ុន្តែសំខាន់ជាងគេ គឺការរីកដុះដាលខាងជំនួញ សណ្ឋាគារនិងភោជនីយដ្ឋាន អចលនទ្រព្យ សេវាកម្មជំនួញ និងសេវាកម្មផ្សេងទៀត ។ ទេសចរណ៍ មានចំណងទាក់ទងខាងដើមខ្សែ និងខាងចុងខ្សែជាមួយនឹងវិស័យដទៃៗទៀត ប៉ុន្តែថ្វីបើមានកំនើនយ៉ាងខ្លាំងក្នុងវិស័យទេសចរណ៍ក៏ដោយ ក៏ផលិតផលកសិកម្មក្នុងស្រុកមិនបានយកទៅប្រើប្រាស់អោយបានទូលំទូលាយនៅតាមភោជនីយដ្ឋាននានាទេ ពីព្រោះការផ្គត់ផ្គង់មិនសូវទៀងទាត់ទេ ហើយគុណភាពក៏ប្រែប្រួលដែរ ។ ប្រទេសកម្ពុជាអាចពង្រឹងចំណងទាក់ទងរវាងវិស័យទេសចរណ៍ និងកសិកម្មបាន ដោយជំរុញអោយមានការផ្គត់ផ្គង់ក្នុងស្រុកយ៉ាងទៀងទាត់ នូវម្ហូបអាហារមានគុណភាពខ្ពស់ ។

អចលនទ្រព្យ និងសេវាកម្មជំនួញ មានកំនើនមាំទាំល្អ ប៉ុន្តែក្នុងនេះ ការរីកដុះដាលនៃផ្នែកអចលនទ្រព្យ បានចូលរួមចំណែកខ្លាំងក្លាជាងសេវាកម្មជំនួញ ។ សេវាកម្មដទៃៗទៀតបានរីកលូតលាស់គួរអោយចាប់អារម្មណ៍ណាស់ ជាអាទិ៍ សេវាកម្មឯកជនផ្ដល់ការអប់រំនិងថែទាំសុខភាព សេវាកម្មលំហែកំសាន្ត សេវាកម្មសហគមន៍ និងសេវាកម្មកែសម្ផស្ស ។

គួរកត់ចំណាំថា តួលេខ ផសស ត្រូវកែតំរូវឡើងវិញនៅពេលមានការពង្រីកដែនគ្របដណ្ដប់ និងទទួលបានទិន្នន័យអាចទុកចិត្តបានច្រើនថែមទៀត ។

## ការកែតំរូវតួលេខ ផសស

NIS បានបន្តកែលំអទិន្នន័យ ផសស រៀងរាល់ឆ្នាំ ដើម្បីបង្កើនភាពត្រឹមត្រូវនៃការប៉ាន់ស្មាន ។ ការកែតំរូវឡើងវិញត្រូវធ្វើជាចាំបាច់ ពីព្រោះនៅពេល NIS បានកើនកំរិតជំនាញក្នុងការប៉ាន់ស្មានពីចំនូលជាតិ NIS ក៏អាចពង្រីកសកម្មភាពសេដ្ឋកិច្ចដែលដាក់បញ្ចូលនៅក្នុងគណនី ហើយអាចទទួលបានទិន្នន័យកាន់តែប្រសើរឡើង ។ ការកែតំរូវដែលកំពុងអនុវត្ត ជាសញ្ញានៃកំនើនគុណភាពទិន្នន័យដែលនាំឱ្យមានកំនើនគុណភាពតួលេខប៉ាន់ស្មាននៃចំណូលជាតិ ។

ការផ្លាស់ប្ដូរជាចំបង៧ចុងក្រោយនេះ ឆ្លុះបញ្ចាំងជាសំខាន់ពីការពង្រីកទំហំគ្របដណ្ដប់លើសកម្មភាពសេដ្ឋកិច្ច ទិន្នន័យកែតំរូវឡើងវិញបានពីបណ្ដាស្ថាប័នរដ្ឋាភិបាល ក្រសួង និងអង្គការផ្សេងៗទៀត ហើយនិងការកែតំរូវវិធីចងក្រងទិន្នន័យ ។ ទំហំគ្របដណ្ដប់បានពង្រីកបន្ថែមដើម្បីរួមបញ្ចូលទាំងផលិតផលដូងប្រេង ការប្រមាញ់និងសត្វព្រៃ និងការប្រមូលយកផលិតផលមិនមែនឈើ ។ កំណែលំអវិធីចងក្រងទិន្នន័យក៏មានផងដែរនូវ ការប៉ាន់ស្មានកាន់តែច្បាស់នូវផលិតផលមិនមែនលោហៈ និងផលិតផលលោហៈ ដើម្បីឱ្យកាន់តែស៊ីគ្នាជាមួយតំរូវការនៃឧស្សាហកម្មសាងសង់ ការផ្លាស់ប្ដូរនៅក្នុងពាណិជ្ជកម្ម និងការដឹកជញ្ជូនចាប់ពីឆ្នាំ២០០០មក ព្រមទាំងការប្រែប្រួលនៃសន្ទស្សន៍បរិត្តផរណានៃថ្លៃ ដែលបានប្រើប្រាស់សំរាប់សកម្មភាពហិរញ្ញវត្ថុ និងរដ្ឋបាលសាធារណៈចាប់ពីឆ្នាំ២០០៣ ។ បន្ថែមទៅលើការកែតំរូវ ដែលផុសចេញពីការប្រែប្រួលទំហំគ្របដណ្ដប់ និងវិធីចងក្រងទិន្នន័យ NIS ក៏បានដាក់បញ្ចូលនូវការផ្លាស់ប្ដូរទាក់ទងទៅនឹងប្រភពទិន្នន័យ ដូចជា ទិន្នន័យកែតំរូវបានមកពីក្រសួងមួយចំនួន និងធនាគារជាតិនៃកម្ពុជា។

*តារាង ៤. លទ្ធផលវិស័យសេវាកម្មៈ ឆ្នាំ២០០៥-២០០៦ (គិតជា%)*

| | អត្រាកំនើនពិត | | ចំនែកក្នុង ផសស | | ចំនែកក្នុង កំនើន ផសស | |
|---|---|---|---|---|---|---|
| | 2005 | 2006 | 2005 | 2006 | 2005 | 2006 |
| សេវាកម្ម | **12.7** | **10.3** | **38.4** | **38.2** | **4.9** | **3.9** |
| ជំនួញ | 8.5 | 7.1 | 8.7 | 8.4 | 0.8 | 0.6 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 22.3 | 13.2 | 4.3 | 4.4 | 0.9 | 0.6 |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | 13.3 | 4.3 | 6.8 | 6.4 | 0.9 | 0.3 |
| ហិរញ្ញវត្ថុ | 19.6 | 24 | 1.1 | 1.3 | 0.2 | 0.3 |
| រដ្ឋបាលសាធារណៈ | 5.9 | -1.2 | 1.5 | 1.4 | 0.1 | 0 |
| អចលនទ្រព្យ និង សេវាកម្មជំនួញ | 7.8 | 10.9 | 7.6 | 7.6 | 0.6 | 0.8 |
| សេវាកម្មផ្សេងៗទៀត | 17.4 | 16.7 | 8.3 | 8.7 | 1.4 | 1.4 |

*ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

*តារាង ៥. ការកែតំរូវតួលេខប៉ាន់ស្មាននៃផលិតកម្ម គិតតាមថ្លៃថេរ*

| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការកែតំរូវ (ពាន់លានរៀល) | 26 | 20 | 13 | 20 | 18 | 25 | -46 | -7 | 46 | 101 | 96 | 117 | 143 |
| ទិន្នន័យកែតំរូវ | -23 | -31 | -39 | -33 | -36 | -31 | -103 | -64 | 34 | 64 | 30 | 23 | 12 |
| កំណែលំអ ទំហំគ្របដណ្ដប់ | 49 | 51 | 52 | 54 | 55 | 56 | 57 | 57 | 0 | 0 | 0 | 0 | 0 |
| ការផ្លាស់ប្ដូរ ក្នុងវិធីសាស្ត្រ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 12 | 37 | 67 | 94 | 131 |
| ការកែតំរូវ (%) | 0.3 | 0.2 | 0.1 | 0.2 | 0.2 | 0.2 | -0.4 | 0 | 0.3 | 0.6 | 0.6 | 0.6 | 0.7 |
| កំនើន ផសស ពិត | | | | | | | | | | | | | |
| ការផ្សព្វផ្សាយដំបូង ឆ្នាំ២០០៦ | | 9.1 | 6.4 | 5.4 | 5.6 | 5 | 11.9 | 8.8 | 8 | 6.5 | 8.5 | 10 | 13.5 |
| ការបោះផ្សាយពីមុន | | 9.2 | 6.5 | 5.3 | 5.7 | 5 | 12.6 | 8.4 | 7.7 | 6.2 | 8.6 | 10 | 13.4 |
| ការកែតំរូវ | | -0.1 | -0.1 | 0.1 | 0 | 0 | -0.6 | 0.3 | 0.4 | 0.3 | -0.1 | 0.1 | 0.1 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ២០០៧*

ដូចមានចុះក្នុងតារាង ៥ ការកែតំរូវលើតួលេខប៉ាន់ស្មានពីមុននាំឱ្យមានការកែតំរូវតួលេខសរុបនៃ ផសស គិតតាមថ្លៃថេរ ដោយតំលើងជាមធ្យម ០,៣% ក្នុងនេះមានការកែតំរូវតំលើង ០,៣% សំរាប់ឆ្នាំ១៩៩៣ និង ០,៧% សំរាប់ឆ្នាំ២០០៥ ។ ការកែតំរូវទាំងនេះ ក៏នាំឱ្យមានការប្រែប្រួលបន្តិចបន្តួចនៅក្នុងអត្រាកំនើនចារិក និងអត្រាកំនើនពិត ។

ការផ្ដល់មតិពីអ្នកប្រើប្រាស់ទិន្នន័យ ជាពិសេសអ្នកប្រើប្រាស់ការវិភាគតាមកំរងទិន្នន័យពីមួយឆ្នាំទៅមួយឆ្នាំ បានជំរុញអោយ NIS ផ្លាស់ប្ដូរនយោបាយកែតំរូវរបស់ខ្លួននៅឆ្នាំ២០០៥ ដោយ NIS ស្នើឡើងថា នៅពេលអនាគត កំរងទិន្នន័យនឹងមានបញ្ចូលតែការកែតំរូវថយក្រោយត្រឹមឆ្នាំ២០០១ ប៉ុណ្ណោះ ។ ប៉ុន្តែតួលេខប៉ាន់ស្មានក្នុងគណនីជាតិបច្ចុប្បន្ន មានបញ្ចូលការប្រែប្រួលក្នុងទំហំគ្របដណ្ដប់ និងការកែតំរូវដល់ឆ្នាំ១៩៩៣ (តារាង ៥) ។ កញ្ញា អ៊ូច ច័ន្ទតារានី និង លោក Keith Carpenter (២០០៦) បានតស៊ូមតិឱ្យមានការកែតំរូវពេញលេញនូវកំរងទិន្នន័យ ដើម្បីទទួលបានតួលេខល្អប្រសើរនៃគណនីជាតិ ។ វាជារឿងល្អណាស់ដែលបានឃើញថា មានការកែតំរូវពេញលេញសំរាប់តួលេខប៉ាន់ស្មានបច្ចុប្បន្ននេះ ។

ទោះបីគុណភាពតួលេខប៉ាន់ស្មានបានកើនឡើងក្ដី ប៉ុន្តែនៅតែមានឧបសគ្គខ្លះដោយសារកង្វះព័ត៌មានតាមវិស័យ ដែលគ្រប់ជ្រុងជ្រោយ និងគួរឱ្យទុកចិត្តបាន ។ សំរាប់តួលេខនៃវិស័យសេវាកម្ម តាមមើលប្រហែលមិនទាន់មានតួលេខត្រឹមត្រូវល្អ នៃចំនួនមន្ត្រីរាជការទេ ។ ដូច្នេះការចូលរួមចំណែកនៃអនុវិស័យរដ្ឋបាលសាធារណៈនៅក្នុង ផសស មិនអាចវាស់វែងបានច្បាស់លាស់ទេ ហើយផលិតភាពរបស់វាក៏មិនអាចប៉ាន់ស្មានបានច្បាស់ដែរ ។ យោងតាមការប្រសើរឡើងនាពេលថ្មីៗនៅក្នុងរដ្ឋបាលស៊ីវិល និងគណនេយ្យសាធារណៈ ការប៉ាន់ស្មានឱ្យបានត្រឹមត្រូវ នូវចំនួនមន្ត្រីរាជការ ហាក់ដូចជាមិនលំបាកពេកទេ ។ ច្បាប់ស្ថិតិតំរូវអោយអ្នកឆ្លើយសំភាសន៍ផ្ដល់ "ព័ត៌មានត្រឹមត្រូវ ពេញលេញ និងទាន់ពេល ដល់មន្ត្រីស្ថិតិមានការចាត់តាំង" ហើយនេះជាចំនុចតូចមួយដែលរដ្ឋាភិបាលអាចផ្ដល់នូវគំរូល្អដល់សង្គមស៊ីវិលបាន ។

ជាទូទៅ គណនីជាតិសំរាប់ឆ្នាំ២០០៦ នៅតែត្រូវប៉ះពាល់ដោយកង្វះប្រភពទិន្នន័យសំរាប់វិស័យសំខាន់ៗមួយចំនួន ដូចជា ទិន្នន័យអង្កេតប្រចាំឆ្នាំលើគ្រឹះស្ថានវិសហគ្រាស ទិន្នន័យអង្កេតប្រចាំឆ្នាំលើកំលាំងពលកម្ម ព្រមទាំងកង្វះខាតជាបន្តនូវ សន្ទស្សន៍ថ្លៃសំរាប់ផលិតករ ពាណិជ្ជកម្មការនាំចេញ និងការនាំចូល ។ ការចងក្រងសន្ទស្សន៍ថ្លៃសំរាប់ផលិតករម្នាក់ (PPI) បានចាប់ផ្ដើមសាកល្បងធ្វើនៅឆ្នាំ២០០៥ តែត្រូវផ្អាកទៅវិញដោយសារខ្វះខាតធនធាន ហើយរឿងនេះ បានប៉ះពាល់មិនល្អទៅលើគុណភាពនៃការប៉ាន់ស្មាន ផសស ។

## សេចក្ដីសន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជា ថ្វីបើមានមូលដ្ឋានតូចចង្អៀត ប៉ុន្តែបានបន្តកើនឡើងយ៉ាងមាំមួនក្នុងឆ្នាំ២០០៦ ហើយកត្តាជំរុញសំខាន់គឺ ការរីកលូតលាស់ក្នុងផលិតកម្មកាត់ដេរ និងការរីកចំរើនដ៏ខ្លាំងក្លានៃទេសចរណ៍ ។ ប៉ុន្តែ ចំណងផ្សារភ្ជាប់រវាងអនុវិស័យទាំងពីរ និងផ្នែកផ្សេងៗទៀតក្នុងសេដ្ឋកិច្ច នៅមិនទាន់រឹងមាំទេ ។ យោងតាមការផ្លាស់ប្ដូរក្នុងគោលនយោបាយអន្តរជាតិដែលគ្រប់គ្រងពាណិជ្ជកម្មវាយនភ័ណ្ឌនិងសំលៀកបំពាក់ កិច្ចប្រឹងប្រែងបច្ចុប្បន្ន សំដៅបង្កើនផលិតភាព និងក៏រឹតប្រកួតប្រជែងនៃវិស័យកាត់ដេរ ក៏ដូចជាការធ្វើចំរុះកម្មទំនិញនាំចេញ គឺចាំបាច់បំផុតដើម្បីជំរុញកំនើនសេដ្ឋកិច្ចបន្ថែមទៀត ។

## កំណត់សំគាល់

១.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (២០០៧)
២.អេង នេត្រា និង ភឹម រ៉ុនស៊ីណារិទ្ធិ (២០០៧)
៣.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាៈ ព័ត៌មានវិនិយោគ
http://www.cambodiainvestment.gov.kh ។

## ឯកសារយោង

Council for the Development of Cambodia, Investment Information, http://www.cambodiainvestment.gov.kh/

Eng Netra & Phim Runsinarith (2007), "Cambodia: A Macro View from 2007 to the Medium Term—Key Indicators for Growth, Development and Shared Prosperity", *Cambodia Development Review,* Volume11, Issue 2 (Phnom Penh: Cambodia Development Resource Institute)

Ministry of Agriculture, Forestry and Fisheries (2007), "Annual Report on Agriculture, Forestry and Fisheries 2006-2007" (Phnom Penh)

National Institute of Statistics (2007), "National Accounts of Cambodia 1993-2006" (Phnom Penh)

Ouch Chandarany and Keith Carpenter (2006), "Solid Economic Growth and Improved Accounting Methodology: A Review of the Cambodian National Accounts Estimates for 2005", *Cambodia Development Review,* Volume 10, Issue 3 (Phnom Penh: Cambodia Development Resource Institute)

# តើគ្រួសារស្ត្រីមេគ្រួនៅជនបទ ទាំងអស់សុទ្ធតែក្រ រឺយ៉ាងណា?

*លោក Brett M. Ballard និងលោកស្រី Ingrid FitzGerald ពិនិត្យពីទំនាក់ទំនងរវាងភេទនៃមេគ្រួសារនៅជនបទ ហើយនិងអថេរសំខាន់ៗមួយចំនួនទាក់ទិននឹងបញ្ហាដីធ្លី ដូចជា ទំហំដីកាន់កាប់ លទ្ធកម្មដីធ្លី ទ្រព្យសម្បត្តិនិងចំណូលគ្រួសារ ធនធានកំលាំងពលកម្ម ការមានស្រូវអង្ករហូបគ្រប់គ្រាន់ និងវិនិយោគលើផលិតកម្មស្រូវ ។**

ឯកសារអន្តរជាតិ និងឯកសារទាក់ទិននឹងកម្ពុជាបានបង្ហាញថា គ្រួសារស្ត្រីមេគ្រួជាទូទៅច្រើនតែក្រីក្រ ។ ប៉ុន្តែភស្តុតាងថ្មីៗបានពីការសិក្សាជាច្រើនរបស់វិទ្យាស្ថាន CDRI បានបង្ហាញផ្ទុយពីនេះ ហើយអាចជះឥទ្ធិពលយ៉ាងច្រើនទៅលើគោលនយោបាយ ។

អត្ថបទនេះពិនិត្យពីទំនាក់ទំនងរវាងភេទនៃមេគ្រួសារនៅជនបទ ហើយនិងអថេរសំខាន់ៗមួយចំនួន ទាក់ទិននឹងបញ្ហាដីធ្លី ដូចជា ទំហំដីកាន់កាប់ លទ្ធកម្មដីធ្លី ទ្រព្យសម្បត្តិនិងចំណូលគ្រួសារ ធនធានកំលាំងពលកម្ម ការមានស្រូវអង្ករហូបគ្រប់គ្រាន់ និងវិនិយោគលើផលិតកម្មស្រូវ ។ មានលំនាំសំខាន់ៗពីរ ដែលពិនិត្យឃើញតាមទិន្នន័យប្រមូលបាននៅដើមឆ្នាំ២០០៤ សម្រាប់អង្កេតមូលដ្ឋានលើការផ្ដល់កម្មសិទ្ធិដីធ្លី ដែលវិទ្យាស្ថាន CDRI បានធ្វើឡើងសំរាប់គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ។[1] លំនាំទី១ គឺគ្រួសារស្ត្រីមេគ្រួ តែងមានលទ្ធភាពប្រើប្រាស់និងគ្រប់គ្រង ទ្រព្យផលិតកម្មតិចជាងគ្រួសារបុរសមេគ្រួ នៅក្នុងគ្រប់ក្រុមកាន់កាប់ដី ។ ថ្វីបើលំនាំនេះ បានបញ្ជាក់គាំទ្រដល់ចំណាប់អារម្មណ៍ជាទូទៅថា នៅក្នុងសង្គមជនបទ គ្រួសារស្ត្រីមេគ្រួតែងងាយធ្លាក់ចូល និងជាប់ផុងជាងគេ នៅក្នុងភាពក្រីក្រក៏ដោយ ប៉ុន្តែលំនាំទី២ បង្ហាញពីភាពខុសគ្នាយ៉ាងច្រើនរវាង គ្រួសារស្ត្រីមេគ្រួមានចំណូលទាប និងមានចំណូលខ្ពស់ បើគិតតាមលទ្ធភាពប្រើប្រាស់និង គ្រប់គ្រងលើទ្រព្យផលិតកម្ម ។ ចំណុចនេះបង្ហាញថា គ្រួសារស្ត្រីមេគ្រួ បានប្រើប្រាស់យុទ្ធសាស្ត្ររកចិញ្ចឹមជីវិតខុសៗគ្នា អាស្រ័យទៅតាមទ្រព្យសម្បត្តិ និងកម្លាំងពលកម្មដែលគេមាន ។ ការសង្កេតឃើញទាំងពីរនេះ អាចជួយដល់អ្នកកសាងគោលនយោបាយអោយរចនារៀបចំ និងកំណត់មុខសញ្ញាអន្តរាគមន៍កាត់បន្ថយភាពក្រីក្រ បានកាន់តែប្រសើរថែមទៀត ។

## ការកាន់កាប់ដីធ្លី

ជាទូទៅ ចំនួន និងទំហំក្បាលដីកសិកម្មជាមធ្យម កើនឡើងជាបណ្តើរៗស្របតាមទំហំដីកាន់កាប់សរុបតាមគ្រួសារ ។ លំនាំនេះឃើញមានទាំងសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។ ទោះជាយ៉ាងនេះក្តី ចំនួន និងទំហំក្បាលដីកាន់កាប់ដោយគ្រួសារស្ត្រីមេគ្រួ ជាមធ្យមមានតិចជាងគ្រួសារបុរសមេគ្រួ ។ តារាង ១ បង្ហាញថា គ្រួសារបុរសមេគ្រួកាន់កាប់ ៤,៤៤ក្បាលដី ក្នុងមួយគ្រួសារ ដែលមានទំហំ ០,៣៩ហិកតា/ក្បាលដី រីឯគ្រួសារស្ត្រីមេគ្រួ កាន់កាប់ជាមធ្យម ៣,៧៨ក្បាលដី ដែលមានទំហំជាមធ្យម ០,៣០ហិកតា/ក្បាលដី ។

*តារាង ១. ទិន្នន័យសង្ខេបពីដីកសិកម្មបែងចែកតាមយេនឌ័រ*

| ទំហំដី (ហិកតា) | ចំនួនគ្រួសារ | | ផ្ទៃដី/គ្រួសារ | | ក្បាលដី/គ្រួសារ | | ផ្ទៃដី/ក្បាលដី | |
|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| < 0.5 | 123 | 78 | 0.28 | 0.26 | 2.28 | 2.36 | 0.12 | 0.11 |
| 0.5 – 0.99 | 164 | 59 | 0.70 | 0.69 | 3.78 | 3.89 | 0.18 | 0.18 |
| 1.0 – 1.99 | 180 | 49 | 1.40 | 1.40 | 4.86 | 4.40 | 0.28 | 0.31 |
| 2.0 – 2.99 | 102 | 20 | 2.43 | 2.29 | 5.29 | 5.65 | 0.46 | 0.40 |
| > 3.0 | 113 | 19 | 5.36 | 4.59 | 6.32 | 5.89 | 0.76 | 0.77 |
| សរុប | 682 | 225 | 1.75 | 1.17 | 4.44 | 3.78 | 0.39 | 0.30 |

ទិន្នន័យអង្កេតមូលដ្ឋានក៏បង្ហាញដែរថា គ្រួសារស្ត្រីមេគ្រួ ៣៤% មានដីកសិកម្មតិចជាង ០,៥ហិកតា ធៀបនឹង ១៨% សំរាប់គ្រួសារបុរសមេគ្រួ ។ ដូចគ្នាដែរ គ្រួសារស្ត្រីមេគ្រួ ៦០% កាន់កាប់ដីតិចជាង ១ហិកតា ហើយសំរាប់គ្រួសារបុរសមេគ្រួ គឺ ៤២% ។ ផ្ទុយទៅវិញ គ្រួសារស្ត្រីមេគ្រួ ១៧% កាន់កាប់ដីច្រើនជាង ២ហិកតា រីឯគ្រួសារបុរសមេគ្រួ មានដល់ ៣១% ។ លំនាំនៃការបែងចែកដីនេះ ជះឥទ្ធិពលយ៉ាងច្រើនទៅលើផលិតភាព និងប្រាក់ចំណូលពីការធ្វើកសិកម្ម ។ ជារួម ការណ៍នេះបង្ហាញថា ការពុះចែកក្បាលដីកាន់តែតូចទៅៗ ទំនងជានឹងមានច្រើននៅខាងគ្រួសារស្ត្រីមេគ្រួ[2] រីឯការប្រមូលផ្តុំ និងគួបបញ្ចូលគ្នានៃដីធ្លី ទំនងជាកើតមានភាគច្រើននៅខាងគ្រួសារបុរសមេគ្រួ ។ មតិទាំងពីរនេះត្រូវតែផ្ទៀងផ្ទាត់ថែមទៀតដោយការស្រាវជ្រាវ ដែលផ្តោតជាពិសេសទៅលើគ្រួសារគ្រប់គ្រងដោយស្ត្រីមេម៉ាយនៅជនបទ ។

## ការទទួលបានដីធ្លី

របៀបនៃការទទួលបានដីធ្លី ក៏បង្ហាញពីកត្តាសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងទំនាក់ទំនងរវាងយេនឌ័រនៃមេគ្រួសារ និងកម្មសិទ្ធិដីធ្លី ។ តារាង ២ បង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលទទួលបានក្បាលដីពីរដ្ឋ មាន ៧០,៩% គឺខ្ពស់ជាងគ្រួសារបុរសមេគ្រួ (៥១,៣%) ។ ភាគរយគ្រួសារស្រីមេគ្រួដែលទទួលបានក្បាលដីតាមរយៈកេរ្តិ៍មរតក (១១,%) មានកំរិតទាបខ្លាំងជាង គ្រួសារបុរសមេគ្រួ (២៤,៦%) ។ ភាពខុសគ្នានេះ គ្មានអ្វីគួរភ្ញាក់ផ្អើលទេ យោងតាមរបៀបរបបជាប្រពៃណីនៅជនបទកម្ពុជា ដែលដីធ្លីតែងប្រគល់ទៅអោយកូនប្រុស ។

*តារាង ២. ការទទួលបានដីធ្លី បែងចែកតាមយេនឌ័រ (%)*

| ទំហំដី (ហិកតា) | បានពីរដ្ឋ | | មរតក | | ទិញ | | ការរានដីព្រៃ | |
|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| < 0.5 | 39.5 | 73.1 | 43.1 | 19.4 | 14.9 | 6.5 | 2.5 | 1.1 |
| 0.5 – 0.9 | 52.0 | 71.6 | 29.6 | 6.7 | 15.7 | 16.4 | 2.6 | 4.9 |
| 1.0 – 1.9 | 58.7 | 77.9 | 21.5 | 6.9 | 14.9 | 8.3 | 4.9 | 6.9 |
| 2.0 – 2.9 | 51.5 | 73.5 | 18.5 | 12.4 | 18.5 | 6.2 | 11.4 | 8.0 |
| > 3.0 | 46.1 | 50.0 | 22.1 | 12.5 | 16.7 | 22.3 | 15.2 | 15.2 |
| សរុប | 51.3 | 70.9 | 24.7 | 11.0 | 16.1 | 11.6 | 7.8 | 6.3 |

* លោក Brett M. Ballard ជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់ ហើយលោកស្រី Ingrid FitzGerald ជាទីប្រឹក្សាខាងយេនឌ័រនៅវិទ្យាស្ថាន CDRI ។ តារាងទិន្នន័យប្រើប្រាស់ក្នុងអត្ថបទនេះ ធ្វើឡើងដោយលោក សូ សុវណ្ណារិទ្ធិ ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណផងដែរដល់លោក ភីម រុនស៊ីណារិទ្ធិ ដែលបានជួយដល់ការវិភាគទិន្នន័យ ។

*តារាង ៣. ទ្រព្យសម្បត្តិ និងកម្លាំងពលកម្មគ្រួសារ (តម្លៃមធ្យមគិតជាម៉ឺនរៀល/គ្រួសារ)*

| ទំហំដី (ហ.ត) | បសុសត្វ * | | ទ្រព្យជាប់លាប់ | | ទ្រព្យជាប់លាប់ មិនសំរាប់ធ្វើកសិកម្ម | | ទ្រព្យធ្វើកសិកម្ម មិនមែនម៉ាស៊ីន | | ទ្រព្យធ្វើកសិកម្ម ជាម៉ាស៊ីន | | ពលកម្ម គ្រួសារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | 54.7 | 41.3 | | | | | | | | | 4.1 | 4.6 |
| < 0.5 | 111.8 | 87.6 | 36.4 | 28.1 | 29.9 | 2.4 | 3.7 | 3.4 | 9.2 | 2.0 | 3.6 | 2.9 |
| 0.5 – 0.99 | 167.0 | 150.7 | 40.7 | 37.8 | 10.4 | 3.3 | 11.2 | 5.8 | 22.1 | 3.4 | 4.2 | 3.8 |
| 1.0 – 1.99 | 212.2 | 127.0 | 62.4 | 14.1 | 23.9 | 0.8 | 14.8 | 9.5 | 36.7 | 5.2 | 4.5 | 2.2 |
| 2.0 – 2.99 | 245.9 | 129.9 | 51.7 | 27.8 | 12.8 | 5.3 | 23.5 | 13.2 | 41.5 | 11.6 | 4.9 | 4.4 |
| > 3.0 | 309.4 | 318.7 | 60.6 | 43.5 | 24.6 | 22.3 | 40.2 | 20.2 | 45.9 | 29.6 | 5.1 | 4.4 |
| សរុប | 197.4 | 128.7 | 50.7 | 28.8 | 20.4 | 4.1 | 18.2 | 7.8 | 31.4 | 6.7 | 4.4 | 3.4 |

* N= *៨៨៨គ្រួសារ រាយការណ៍ពីការគ្រប់គ្រងលើបសុសត្វ*

តារាង ២ បង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលទទួលបានក្បាលដីតាមរយៈការទិញ និងការរានដីព្រៃ គឺមានតិចជាង គ្រួសារបុរសមេគ្រួ ។ ដូច្នេះគួបផ្សំគ្នាមក ភាគរយទាបនៃការផ្ទេរមរតក ការទិញ និងការរានដីព្រៃបង្ហាញថា គ្រួសារស្ត្រីមេគ្រួ មានលទ្ធភាពទទួលបានក្បាលដីបន្ថែម តិចជាងគ្រួសារបុរសមេគ្រួ លើកលែងតែគ្រួសារដែលមានដីចាប់ពី ៣ហិកតាឡើងទៅ ។ តារាង ៣ ជួយបញ្ជាក់ពីការសង្កេតឃើញនេះដោយបង្ហាញថា គ្រួសារស្ត្រីមេគ្រួនៅក្នុងក្រុមកាន់កាប់ដីនីមួយៗ ជាមធ្យមមានទ្រព្យសម្បត្តិ និងប្រាក់ចំណូល តិចជាងគ្រួសារបុរសមេគ្រួ ។ ទ្រព្យសម្បត្តិតិចជាង ជាពិសេសទ្រព្យសំរាប់ធ្វើកសិកម្ម និងកម្លាំងពលកម្មមនុស្សពេញវ័យ វាជាកំហិតកំណត់ចំនួនដីធ្លីដែលអាចធ្វើកសិកម្ម រឺរានយកបាន រឺឯប្រាក់ចំណូលទាប វាជាកំហិតកំណត់លើការទិញដីបន្ថែម ។

## ផលស្រូវគ្រប់គ្រាន់

តាមធម្មតា ផលស្រូវពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងទំហំដីកាន់កាប់ ។ ជាទូទៅ ភាគរយនៃគ្រួសារដែលផលិតស្រូវបានគ្រប់គ្រាន់ រឺមានអតិរេក តែងកើនឡើងទៅតាមទំហំដីកាន់កាប់ រីឯភាគរយគ្រួសារដែលត្រូវទិញស្រូវអង្ករសំរាប់បរិភោគចាប់ពី ៩ខែឡើងទៅក្នុងមួយឆ្នាំ វាថយចុះយ៉ាងខ្លាំងនៅពេលទំហំដីកាន់កាប់កើនឡើង ។ គ្រួសារកាន់កាប់ដីធំ ក៏មានប្រៀបជាច្រើនទៀតទៅលើគ្រួសារកាន់កាប់ដីតូច ។ ឧទាហរណ៍ គ្រួសារមានដី ៣ហិកតាឡើងទៅ តំណាងឱ្យ ២៣% នៃគ្រួសារដែលផលិតស្រូវមានអតិរេក ទោះបីនៅក្នុងគំរូតាង ពួកគេតំណាងឱ្យតែ ១៣% ក៏ដោយ ។ គ្រួសារមានដី ០,៥ហិកតា រឺតិចជាង (រួមទាំងអ្នកអត់ដី) តំណាងឱ្យ ៦,៨% នៃអ្នកផលិតស្រូវមានអតិរេក ប៉ុន្តែនៅក្នុងចំនួនសរុប ពួកគេតំណាងឱ្យ ២៧% ។ គ្រួសារអត់ដី តំណាងឱ្យ ៣៧% នៃគ្រួសារត្រូវទិញស្រូវទាំងអស់ ប៉ុន្តែពួកគេមានចំនួនស្មើនឹង ៦,៣% នៃគ្រួសារនៅក្នុងអង្កេតប៉ុណ្ណោះ ។

ចំនុចគួរអោយចាប់អារម្មណ៍គឺ គ្រួសារមានដីចាប់ពី ២ហិកតាឡើងទៅ មានចំនួនស្មើ ២៤% នៃគ្រួសារដែលត្រូវទិញស្រូវអង្ករសំរាប់ហូបទាំងអស់ ។ បើគិតមួយភ្លែត រឿងនេះហាក់ដូចមិនត្រឹមត្រូវទេ ពីព្រោះគេតែងរំពឹងថា គ្រួសារមានដីធំដូច្នេះ យ៉ាងហោចណាស់ក៏អាចផលិតស្រូវបានខ្លះដែរ ។ ការបាត់បង់ផលស្រូវបែបនេះ អាចពន្យល់មួយបែបថា មកពីមានសត្វល្អិត ទឹកជំនន់ និងការរាំងស្ងួតបំផ្លាញអស់ ។ មូលហេតុនេះក៏ជួយពន្យល់ថា ហេតុអ្វីបានជាអ្នកមានដីតូចៗជាច្រើននាក់ត្រូវទិញស្រូវអង្ករសំរាប់ហូប

*តារាង ៤. វត្តមានផលស្រូវគ្រប់ហូប*

| ទំហំដី (ហិកតា) | អតិរេក | | គ្រប់គ្រាន់ | | 7-10 ខែ | | 3-6 ខែ | | < 3 ខែ | | ទិញទាំងអស់ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | 5 | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 1 | 32 | 20 | 40 | 21 |
| < 0.5 | 9 | 5 | 13 | 4 | 32 | 21 | 33 | 20 | 19 | 17 | 17 | 11 | 123 | 78 |
| 0.5 – 0.9 | 52 | 12 | 17 | 13 | 45 | 16 | 25 | 9 | 14 | 3 | 11 | 5 | 164 | 58 |
| 1.0 – 1.9 | 65 | 12 | 33 | 7 | 30 | 7 | 24 | 9 | 15 | 8 | 13 | 6 | 180 | 49 |
| 2.0 – 2.9 | 40 | 10 | 15 | 1 | 13 | 3 | 13 | 0 | 7 | 3 | 14 | 3 | 102 | 20 |
| > 3.0 | 56 | 7 | 17 | 2 | 15 | 1 | 11 | 4 | 9 | 2 | 5 | 3 | 113 | 19 |
| Total N | 227 | 46 | 98 | 27 | 135 | 48 | 106 | 42 | 64 | 34 | 92 | 48 | 722 | 245 |
| % total F/M | 31.4 | 18.8 | 13.6 | 11.0 | 18.7 | 19.6 | 14.9 | 17.1 | 8.9 | 13.9 | 12.7 | 19.6 | | |
| សរុប | 273 | | 125 | | 183 | | 148 | | 98 | | 140 | | 967* | |

*N = *បាត់អស់ ៣ គ្រួសារ*

ទាំងអស់ ។ មតិនេះត្រូវបានបញ្ជាក់គាំទ្រ ដោយទិន្នន័យពាក់ព័ន្ធជាមួយវិបត្តិ/បញ្ហាគ្រួសារ ដែលបង្ហាញថា ៦៧គ្រួសារ នៅក្នុងក្រុមអង្កេត LMAP ក្នុងនេះមានទាំង ១៥គ្រួសារដែលមានដីកសិកម្ម ៣ហិកតា រឺច្រើនជាងផង គឺធ្លាប់ខូចខាតផលដំណាំដោយសារសត្វល្អិត ។ មាន ៣៩៨គ្រួសារ (៧១គ្រួសារមានដីដល់ ៣ហិកតា រឺច្រើនជាង) បានរាយការណ៍ពីការខូចផលដំណាំដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត ។ គួរចងចាំថា នៅឆ្នាំ២០០៣ ដែលជាឆ្នាំចុះប្រមូលទិន្នន័យកសិកម្ម មានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា រួមទាំងតំបន់មួយចំនួននៅក្នុងគំរូតាងអង្កេតនេះផង ។

ទិន្នន័យពីវគ្គមានផលស្រូវគ្រប់ហូបបង្ហាញថា គ្រួសារបុរសមេគ្រួច្រើនមានប្រៀបល្អជាងគ្រួសារស្ត្រីមេគ្រួ ។ ឧទាហរណ៍ គ្រួសារបុរសមេគ្រួតំណាងឱ្យ ៨៣,២%នៃគ្រួសារមានអតិរេកផលស្រូវ ប៉ុន្តែមានចំនួនត្រឹម ៧៤,៦% នៃគ្រួសារទាំងអស់ប៉ុណ្ណោះ ។ គ្រួសារស្ត្រីមេគ្រួ មានចំនួនស្មើនឹង ៣៤% នៃគ្រួសារត្រូវទិញស្រូវអង្ករហូបពេញមួយឆ្នាំ ប៉ុន្តែមានត្រឹម ២៥% នៃគ្រួសារបានចុះអង្កេតប៉ុណ្ណោះ ។ គ្រួសារស្ត្រីមេគ្រួ តំណាងឱ្យ ៥៣,១% នៃគ្រួសារមានផលស្រូវគ្រប់ហូបសំរាប់ ៣ខែ រឺតិចជាង និង ៣៩,៦% នៃគ្រួសារមានផលស្រូវគ្រប់ហូបសំរាប់ ៣ ទៅ ៦ខែ ។ តួលេខនេះអាចបកស្រាយបានថា មកពីគ្រួសារស្ត្រីមេគ្រួមានដីកាន់កាប់តូចៗ ទ្រព្យសម្បត្តិតិចតួច និងកម្លាំងពលកម្មមនុស្សពេញវ័យតិច ។

## ចំណាយលើផលិតកម្មស្រូវ

បន្ថែមពីលើដីធ្លី ទ្រព្យមូលធនផ្សេងទៀត និងកម្លាំងពលកម្ម តួលេខខុសៗគ្នានៃអ្នកមានផលស្រូវគ្រប់ហូប នៅតាមក្រុមអ្នកកាន់កាប់ដីខុសៗគ្នាអាចបកស្រាយបានតាមរយៈទំហំវិនិយោគលើផលិតកម្មស្រូវ ។ តារាង ៥ បង្ហាញថា វិនិយោគលើផលិតកម្មស្រូវជាមធ្យម ជាទូទៅកើនឡើងទៅតាមទំហំដីកាន់កាប់ ។ លំនាំនេះអាចសង្កេតឃើញទាំងសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ នៅតាមគ្រប់ទំហំដីកាន់កាប់ ។ គួរកត់សំគាល់ជាសំខាន់ថា នៅតាមក្រុមកាន់កាប់ដីនីមួយៗ គ្រួសារបុរសមេគ្រួជាទូទៅបានវិនិយោគទៅលើដីកាន់កាប់ ច្រើនជាងគ្រួសារស្ត្រីមេគ្រួ លើកលែងក្នុងក្រុមកាន់កាប់ដីធំបំផុត ដែលគ្រួសារស្ត្រីមេគ្រួបានវិនិយោគជាមធ្យមប្រហែល ៦០ម៉ឺនរៀល /គ្រួសារ ធៀបនឹងត្រឹម ៥០ម៉ឺនរៀល សំរាប់គ្រួសារបុរសមេគ្រួ ។ ដោយសារ គ្រួសារស្ត្រីមេគ្រួជាទូទៅមានកម្លាំងពលកម្មតិច ដូច្នេះពួកគេតែងហ៊ានចំណាយសោហ៊ុយប៉ះប៉ូវកង្វះខាតនេះ នៅពេលពួកគេមានលទ្ធភាព ។

## ការពិភាក្សា

ទិន្នន័យអង្កេតមូលដ្ឋានពីការចុះបញ្ជីដីធ្លីនៅជនបទ បង្ហាញរូបភាពដ៏សំខាន់មួយពីភាពខុសគ្នានៃទ្រព្យសម្បត្តិ របស់គ្រួសារស្ត្រីមេគ្រួ និងគ្រួសារបុរសមេគ្រួ នៅក្នុងក្រុមដីកាន់កាប់នីមួយៗ និងរវាងក្រុមដីកាន់កាប់ខុសៗគ្នា និងបញ្ជាក់គាំទ្រដល់ការសិក្សាដទៃទៀត ដែលគូសរំលេចពីការចាញ់ប្រៀបផ្សេងៗដែលគ្រួសារស្ត្រីមេគ្រួត្រូវជួបប្រទះ ក្នុងការកាន់កាប់ដីឱ្យមានសុវត្ថិភាព និងការរកចិញ្ចឹមជីវិត ។ ប៉ុន្តែត្រង់ចំនុចនេះ មានកង្វះទិន្នន័យសំរាប់សិក្សាពីការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ដូចជា នៅពេលណាដែល ស្ត្រីក្លាយជាមេគ្រួសារមេម៉ាយ ហើយមានអ្វីកើតឡើងចំពោះដីកាន់កាប់ និង ទ្រព្យផ្សេងទៀតរបស់ពួកគេ? យើងអាចសន្មត់បានថា ជាមធ្យមគ្រួសារស្ត្រីមេគ្រួទទួលបានដីតិចជាងនៅពេលបែងចែកដីនៅឆ្នាំ១៩៨៩ ប៉ុន្តែតាំងពីនោះមកតើវាវិវត្តយ៉ាងណាទៀត?

*តារាង ៥. ធាតុចូលសំរាប់ផលិតកម្មស្រូវ (ម៉ឺនរៀល/គ្រួសារ)*

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | សរុបជាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | | |
| ជីគីមី | 5.8 | 5.7 | 10.6 | 8.7 | 12.0 | 8.3 | 13.6 | 8.9 | 17.6 | 32.7 | 11.21 | |
| ថ្នាំសំលាប់សត្វល្អិត | 1.4 | .8 | 2.1 | 1.2 | 2.0 | 1.1 | 1.5 | 1.5 | 3.1 | 3.1 | 2.06 | |
| បូមទឹក | 3.2 | 2.7 | 4.0 | 4.0 | 5.1 | 4.1 | 7.5 | 3.0 | 11.5 | 15.0 | 5.59 | |
| ពលកម្មរៀបចំដី | 4.6 | 3.1 | 6.7 | 5.2 | 11.6 | 7.1 | 10.6 | 5.5 | 18.4 | 17.3 | 9.01 | |
| ពលកម្មស្ទូង | 6.8 | 5.7 | 9.2 | 8.3 | 11.8 | 8.8 | 14.5 | 11.1 | 22.5 | 33.5 | 12.2 | |
| ពលកម្មច្រូតកាត់ | 5.3 | 3.4 | 6.2 | 4.0 | 8.3 | 5.4 | 12.1 | 9.9 | 13.5 | 18.3 | 8.46 | |
| បោកស្រូវ | 2.7 | 2.3 | 2.8 | 2.3 | 3.9 | 3.2 | 5.8 | 3.6 | 6.7 | 9.3 | 4.2 | |
| ជួសជុល | 1.5 | 1.1 | 2.2 | 1.6 | 2.3 | 2.4 | 1.7 | .95 | 1.9 | 15.0 | 2.07 | |
| ដឹកជញ្ជូន | 1.8 | 2.0 | 2.7 | 2.6 | 3.2 | 2.6 | 3.5 | 1.9 | 6.6 | 3.9 | 3.23 | |
| ជួលដី | 7.5 | | 6.1 | 1.7 | 10.8 | | 6.0 | | 10.9 | | 7.7 | |
| ជួលសត្វអូសទាញ | .2 | 5.0 | 4.9 | | 3.2 | 5.0 | | 6.0 | 10.0 | 1.5 | 4.48 | |
| ផ្សេងៗ | 4.6 | .97 | 4.4 | 5.5 | 10.6 | 20.0 | 3.1 | 10.0 | 7.4 | 6.3 | 7.2 | |
| សរុប | 14.4 | 10.8 | 23.1 | 17.0 | 34.4 | 20.0 | 32.8 | 25.0 | 50.7 | 60.2 | 30.7 | 19.8 |
| **សរុប** | 13.03 | | 21.57 | | 31.77 | | 31.6 | | 51.98 | | 28.2 | |

គេតែងគិតថា គ្រួសារស្ត្រីមេគ្រួនៅជនបទ មានស្ថានភាពងាយរងគ្រោះបំផុត និងងាយធ្លាក់ក្នុងភាពក្រីក្រ ហើយគំនិតនេះមានការបញ្ជាក់គាំទ្រពីការសិក្សាវាយតម្លៃពីភាពក្រីក្រដោយមានការចូលរួមរបស់ CDRI (PPA) នៅតំបន់ទន្លេសាបដែលរកឃើញថា គ្រួសារស្ត្រីមេគ្រួភាគច្រើនជាអ្នកក្រ រឺក្រលំបាក់នៅក្នុងគ្រប់ភូមិសិក្សា ទោះពួកគេមានរបបចិញ្ចឹមជីវិតបែបណាក៏ ។ ម្យ៉ាងទៀតនៅតាមតំបន់ជាច្រើន អ្នកភូមិរាយការណ៍ថា គ្រួសារស្ត្រីមេគ្រួក្រីក្រ និងក្រីក្រលំបាក់នៅឆ្នាំ២០០៥ គឺឃើញមានច្រើនជាងនៅឆ្នាំ២០០០ ។

អ្នកវិភាគអន្តរជាតិ និងការសិក្សាថ្មីៗរបស់កម្ពុជា មិនបានយល់ស្របតាមលទ្ធផលរកឃើញនេះទេ[៣] ដោយផ្តល់មតិថា ថ្វីបើគ្រួសារស្ត្រីមេគ្រួច្រើនតែមានជីវភាពលំបាកជាងគ្រួសារបុរសមេគ្រួ ប៉ុន្តែមានការប្រែប្រួលខុសគ្នាជាច្រើននៃប្រាក់ចំណូល ចំណាយប្រើប្រាស់ និងរបាយទ្រព្យសម្បត្តិ នៅក្នុងចំណោមគ្រួសារស្ត្រីមេគ្រួ ។ ឧទាហរណ៍ ការសិក្សាពីការចាកផុតពីភាពក្រីក្រ (MOPS) របស់ CDRI បង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលជាប់ផុងក្នុងភាពក្រីក្រដ៏រ៉ាំរ៉ៃ មានច្រើនជាងគេក៏ពិតមែន ប៉ុន្តែគ្រួសារដែលអាចចាកផុតពីភាពក្រីក្រ រឺក្លាយជាអ្នកធូរធារ ក៏មានច្រើនគួរសមដែរ ។ គិតជាសរុបគ្រួសារស្ត្រីមេគ្រួរកប្រាក់ចំណូលបានតិច និងកាន់កាប់ដីតូចជាងគ្រួសារបុរសមេគ្រួក៏ពិតមែន ប៉ុន្តែគ្រួសារស្ត្រីមេគ្រួដែលធូរធារ គឺមានប្រាក់ចំណូល និងទ្រព្យសម្បត្តិ ប្រហាក់ប្រហែលគ្នានឹងគ្រួសារបុរសមេគ្រួដែលមានជីវភាពធូរធារដែរ ។ គ្រួសារស្ត្រីមេគ្រួដែលមានជីវភាពលានឡើង ក៏ច្រើនតែជាគ្រួសារគ្មានដីកសិកម្មដែរ ដោយពួកគេពឹងផ្អែកលើប្រភពចំណូលដទៃទៀតដែលមិនមែនជាការងារកសិកម្ម ដើម្បីចាកផុតពីភាពក្រីក្រ ។[៤]

ទិន្នន័យអង្កេតមូលដ្ឋានស្តីពីការចុះបញ្ជីដីធ្លីនៅជនបទ បង្ហាញថា ធៀបនឹងគ្រួសារបុរសមេគ្រួ គ្រួសារស្ត្រីមេគ្រួ ច្រើនតែចាញ់ប្រៀបបើគិតតាមទំហំដីកាន់កាប់ និងលំនាំនៃការទទួលបានដីធ្លី ហើយរឿងនេះបណ្តាលមកពីប្រវត្តិនៃការបែងចែកដី កង្វះធនធានមនុស្ស និងកង្វះទ្រព្យសម្បត្តិ ។ ដូចក្នុង MOPS ដែរ ទិន្នន័យអង្កេតមូលដ្ឋាននៅជនបទ បង្ហាញពីភាពខុសគ្នាយ៉ាងច្រើនរវាងគ្រួសារស្ត្រីមេគ្រួនានា ដូច្នេះពួកគេមិនមែនសុទ្ធតែក្រនោះទេ ។ ឧទាហរណ៍ តារាង ១ បង្ហាញថា ១៧% នៃគ្រួសារស្ត្រីមេគ្រួដែលបានចុះអង្កេត មានដីកាន់កាប់ ២ហិកតា រឺច្រើនជាង ។ តារាង ៣ បង្ហាញពីគំលាតដ៏ធំរវាង គ្រួសារកាន់កាប់ដីតូច និងគ្រួសារកាន់កាប់ដីធំ បើពិនិត្យតាមតម្លៃបសុសត្វ និងទ្រព្យមូលធន ។ តារាង ៥ បង្ហាញថា គ្រួសារកាន់កាប់ដីធំវិនិយោគលើផលិតកម្មស្រូវ ស្ទើរតែបួនដងច្រើនជាងគ្រួសារកាន់កាប់ដីតូច ។

លទ្ធផលរកឃើញទាំងនេះ អាចមានប្រយោជន៍ច្រើនដល់ការតម្រង់ទិសគោលនយោបាយអោយមានប្រសិទ្ធភាព ។ ឧទាហរណ៍ ការផ្តួចផ្តើមគំនិតចុះបញ្ជីដីធ្លី គួរតែបន្តប្រឹងប្រែងជាពិសេស ដើម្បីធានាអោយគ្រួសារស្ត្រីមេគ្រួទទួលបានកម្មសិទ្ធិដីធ្លី ។ យោងតាមលំនាំបែងចែកមរតកទៅតាមយេនឌ័រ និង សមត្ថភាពតិចជាង ដើម្បីរក្សាដីកាន់កាប់បច្ចុប្បន្ននិងទទួលបានដីថ្មី យើងឃើញថា សុវត្ថិភាពកម្មសិទ្ធិមានសារៈសំខាន់ណាស់សំរាប់ឱ្យគ្រួសារទាំងនេះអាចការពារទ្រព្យសម្បត្តិដែលមានស្រាប់ និងបង្កើនលទ្ធភាពទទួលបានឥណទានផ្លូវការ ។ លទ្ធភាពទទួលបានឥណទានផ្លូវការ វាសំខាន់ជាពិសេសដោយជួយសំរួលការវិនិយោគច្រើនថែមទៀតទៅក្នុងអាជីវកម្មតូចៗ ដែលជាប្រភពកាន់តែសំខាន់សំរាប់ប្រាក់ចំណូលរបស់គ្រួសារស្ត្រីមេគ្រួ ។ ប័ណ្ណកម្មសិទ្ធិដី អាចជួយឱ្យស្ត្រីជាមេគ្រួសារអាចលក់ដីខ្លួនបានថ្លៃខ្ពស់ ហើយទាញយកចំណេញពីឱកាសល្អៗដើម្បីរកប្រាក់ចំណូលពីមុខរបរក្រៅកសិកម្ម ។ ហើយទោះបីវិធីនេះវាបង្កើនភាពអត់ដីធ្លី រឺស្ទើរអត់ដីធ្លីក្នុងចំណោមគ្រួសារស្ត្រីមេគ្រួក្តី ប៉ុន្តែវាមិនមែនជាលទ្ធផលអវិជ្ជមានទេ បើសិនគេអាចរកបានការងារ/អាជីវកម្មដែលអាចរស់រានបាន ។

ការពិភាក្សាខាងលើ បានបង្ហាញពីតម្រូវការស្រាវជ្រាវបន្ថែមពីការកាន់កាប់ដីនៅកម្ពុជា ដោយផ្តោតជាពិសេសលើបញ្ហាយេនឌ័រ ។ ទិដ្ឋភាពសំខាន់មួយនៃការស្រាវជ្រាវបែបនេះគឺត្រូវពិនិត្យថា តើប័ណ្ណកម្មសិទ្ធិដីបានកែលំអនិងពង្រឹងសុវត្ថិភាពកាន់កាប់ដីរបស់ស្ត្រី (ទាំងនៅក្នុងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ) ព្រមទាំងសុខមាលភាពរបស់គ្រួសារស្ត្រីមេគ្រួដែរឬទេ ។ មួយផ្នែកដ៏សំខាន់នៃការស្រាវជ្រាវ ត្រូវផ្តោតលើយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតនិងប្រភពប្រាក់ចំណូលដោយយោងតាមភេទនៃមេគ្រួសារ ។ ក្នុងករណីទាំងពីរនេះ ត្រូវប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ពីព្រោះបញ្ហាពាក់ព័ន្ធជាច្រើនអាចមានលក្ខណៈរសើប និងស្មុគស្មាញច្រើន ដូច្នេះមិនងាយនឹងក្តាប់បានដោយប្រើឧបករណ៍ស្រាវជ្រាវបែបបរិមាណនោះទេ ។ ពិតហើយក្នុងរឿងសិទ្ធិ និងសុវត្ថិភាពកាន់កាប់ដី ក្នុងនេះមានទាំងការប្រមូលផ្តុំដីធ្លី និងការពុះបំបែកក្បាលដីកាន់តែតូចទៅៗផង មានបញ្ហាជាច្រើនជាប់ពាក់ព័ន្ធនឹងយេនឌ័រ ហើយមានលក្ខណៈដើមបែបសង្គម និងវប្បធម៌ផង ដូច្នេះត្រូវតែប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវមានលក្ខណៈច្នៃប្រឌិតខ្ពស់ ។

## កំណត់សំគាល់

១. ទិន្នន័យការអង្កេតគ្របដណ្តប់លើ ៩៧០គ្រួសារនៅជនបទ ក្នុង ៣២ភូមិក្នុងខេត្ត LMAP ទាំង៤ គឺ កំពង់ចាម កំពង់ធំ ក្រុងព្រះសីហនុ និងតាកែវ ដោយក្នុងនេះ មាន ៦៣គ្រួសាររាយការណ៍ថាគ្មានដីកសិកម្ម ។ ដូច្នេះ ទិន្នន័យនេះសំដៅលើការកាន់កាប់ដីរបស់ ៩០៧គ្រួសារគំរូតាង ដែលមាន ៦៨២គ្រួសារបុរសមេគ្រួ (៧៥,២%) និង ២២៥គ្រួសារស្ត្រីមេគ្រួ (២៤,៨%) ។

២. ការបកស្រាយមួយ គឺអាចមកពីមូលហេតុដែលគ្រួសារត្រូវមានមេគ្រួសារជាស្ត្រី ។ ឧ. ស្ត្រីក្លាយជាមេម៉ាយដោយប្តីស្លាប់ ប្តីលែង រឺប្តីចាកចោល អាចបាត់បង់អស់ទ្រព្យផលិតកម្ម មានទាំងដីធ្លីផង (Fitzgerald 2007)

៣. មើល Chant (២០០៣) សំរាប់ការពិភាក្សាពីបញ្ហាជាប់ទាក់ទងនឹងការសន្មតថា គ្រួសារស្ត្រីមេគ្រួ គឺងាយរងគ្រោះ និង/រឺក្រីក្រ ។ មើល Urashima et al. (2007) សំរាប់ការវិភាគពីភាពខុសគ្នារវាងគ្រួសារស្ត្រីមេគ្រួនៅកម្ពុជា ដោយប្រើទិន្នន័យ CSES ឆ្នាំ២០០៤ ។ ការវិភាគនេះបង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលគ្មានកម្លាំងមនុស្សប្រុសពេញវ័យ និងមានអ្នកនៅក្នុងបន្ទុកច្រើន គឺតែងតែក្រីក្រជាង គ្រួសារដែលមានកម្លាំងមនុស្សប្រុសពេញវ័យ និងមានអ្នកនៅក្នុងបន្ទុកតិចទាក់ ។

៤. ការបកស្រាយមួយចំពោះភាពផ្ទុយគ្នា រវាងលទ្ធផលនៅក្នុងអង្កេតមូលដ្ឋានពីការចុះបញ្ជីដីធ្លីជនបទ ហើយនិង MOPS មួយផ្នែក និង PPA មួយផ្នែកទៀត វាជាប់ទាក់ទិននឹងវិធីសាស្ត្រស្រាវជ្រាវ ។ PPA ផ្តោតលើគ្រួសារ និងសហគមន៍ក្រីក្រ ហើយប្រើវិធីសាស្ត្របែបគុណវិស័យ រីឯ MOPs បានរួមបញ្ចូលគ្រួសារ និងសហគមន៍ក្រីក្រ និងមិនក្រ ទៅក្នុងគំរូតាងរបស់ខ្លួន ។ MOPs បានប្រមូលផ្តុំទិន្នន័យបែបបរិមាណលើទ្រព្យសម្បត្តិ និងការចំណាយរបស់គ្រួសារ ដែលអាចធ្វើការប្រៀបធៀបគ្នាបានរវាងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។

## ឯកសារយោង

*សូមមើលឯកសារយោងក្នុងអត្ថបទភាសាអង់គ្លេស*

# ការស្វែងយល់ពីតួនាទី មូលធនសង្គម នៅពេលមាន ទឹកជំនន់ និងគ្រោះរាំងស្ងួត

*លោកស្រី អាង សូផា លោក អឿ អ៊ុល និង John McAndrew សិក្សាពីតួនាទីមូលធនសង្គម ក្នុងការជួយអ្នកភូមិប្រឈមមុខនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ ក្នុងតំបន់អេកូឡូស៊ីពីរនៅខេត្តកំពង់ធំ ។**

## សេចក្តីផ្តើម

ប្រទេសកម្ពុជា បានឈានចូលសតវត្សរ៍ទី២១ នេះ ដោយសង្ឃឹមថានឹងបានមកដល់សម័យមានសន្តិភាព និងតម្លាភាពហើយ ប៉ុន្តែបែរជារងគ្រោះដោយសារទឹកជំនន់ និងការរាំងស្ងួតអស់ ៥ឆ្នាំជាប់ៗគ្នាទៅវិញ ។ ទឹកជំនន់នៅឆ្នាំ២០០០/០១ ដែលជាគ្រោះធម្មជាតិធ្ងន់ធ្ងរជាងគេក្នុងរយៈ ៧០ឆ្នាំចុងក្រោយ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ ៣,៤លាននាក់ ហើយទឹកជំនន់ឆ្នាំ២០០០/០២ បានប៉ះពាល់ដល់ ប្រជាពលរដ្ឋ ២,១លាននាក់ នៅក្នុងតំបន់ដែលកំពុងរើខ្លួននៅឡើយពីការលិចលង់កាលពីឆ្នាំមុន ។ សំរាប់ការរាំងស្ងួតនៅឆ្នាំ២០០២/០៣ រដ្ឋាភិបាលបានរាយការណ៍ថា ជាគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរបំផុតក្នុងរយៈ ២០ឆ្នាំចុងក្រោយ ហើយបានប៉ះពាល់ដល់ប្រជាជនជាង ២លាននាក់ ។ ការរាំងស្ងួតនៅឆ្នាំ២០០៣/០៤ បានធ្វើឱ្យបឹងនៅតាមកន្លែងទំនាបទាបៗបំផុតនៃវាលលិចទឹក ត្រូវរីងស្ងួតអស់ ។ នៅឆ្នាំ២០០៤/០៥ គ្រោះរាំងស្ងួតបានប៉ះពាល់ដល់ប្រជាជន ២លាននាក់ និងបង្កកង្វះខាតស្បៀងអាហារនៅគ្រប់ទិសទី (Chan 2001; Nhim Vanda 2002; Asian Disaster Reduction Center 2003; Helmers and Jegillos 2004; Mao 2005) ។ អត្ថបទនេះ ពិនិត្យពីផលប៉ះពាល់នៃទឹកជំនន់ និងការរាំងស្ងួត ទៅលើទិន្នផលស្រូវ និងបែបបទនៃការកចិញ្ចឹមជីវិតនៅក្នុងឆ្នាំទាំងនោះ នៅក្នុងឃុំចំនួនពីរដែលមានប្រព័ន្ធអេកូឡូស៊ីខុសគ្នា នៅខេត្តកំពង់ធំ និងស្រាវជ្រាវពីតួនាទីនៃមូលធនសង្គម ដើម្បីជួយប្រជាជនរងគ្រោះអោយប្រឈមមុខដោះស្រាយតំរូវការដ៏ចាំបាច់នានា ។

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់កន្លែងបានធ្វើឡើងនៅខែមិថុនា ឆ្នាំ២០០៥ នៅ ២តំបន់អេកូឡូស៊ី ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ គេបានជ្រើសយក ៣ភូមិ ក្នុងឃុំសានគរ ធ្វើជាតំបន់អេកូឡូស៊ីមួយនៃការសិក្សា ។ ភូមិទាំង៣ ស្ថិតក្នុងតំបន់វាលទំនាបលិចទឹកជិតបឹងទន្លេសាប តាមខាងលិចដងផ្លូវជាតិលេខ៦ នៅជិតផ្សារឃុំសានគរ ។ ភូមិចំនួន ២ ក្នុងឃុំដីវិស្លាប់ បានជ្រើសយកធ្វើជាតំបន់អេកូឡូស៊ីមួយទៀត ។ ភូមិទាំង២ ស្ថិតក្នុងតំបន់ដីខ្ពស់ ខាងក្រៅវាលទំនាបលិចទឹក ជិតបឹងទន្លេសាប តាមខាងកើតដងផ្លូវជាតិលេខ៦ ចំងាយប្រហែល ៨ ទៅ ១២គ.ម ពីផ្សារឃុំសានគរ ។ គិតជាសរុប បានធ្វើអង្កេតលើ ១៥៥គ្រួសារ ក្នុង ៣ភូមិ នៅឃុំសានគរ គឺ ភូមិអំពិល ភូមិជ័យ និងភូមិស្លែងខ្ពស់ និង ១០០គ្រួសារទៀត ក្នុង ២ភូមិ នៅឃុំដីវិស្លាប់ គឺ ភូមិសង្គម និងភូមិវល្លិយាវ ។ ជាបន្ថែមលើអង្កេតនេះ គេបានធ្វើសំភាសន៍ជាលក្ខណៈក្រុមមុខសញ្ញាជាមួយ អាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំក្នុងមូលដ្ឋាន នារីអ្នកភូមិ និងបុរសអ្នកភូមិ ។ ម្យ៉ាងទៀត បានជ្រើសរើសគ្រួសារមួយចំនួន មកធ្វើសំភាសន៍ជាលក្ខណៈអ្នកផ្តល់ព័ត៌មានគន្លឹះ ។[1]

## គោលគំនិតនៃមូលធនសង្គម

គោលគំនិតនៃមូលធនសង្គម អាចមានប្រយោជន៍ច្រើនដល់ការវិភាគពីបែបបទដែលប្រជាជនប្រឈមមុខនឹងគ្រោះធម្មជាតិដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ។ Robert Putnam ដែលជាអ្នកជួយផ្សព្វផ្សាយពីគោលគំនិតនេះ បានអោយនិយមន័យមូលធនសង្គម ថាជា "លក្ខណៈនានានៃការរៀបចំសង្គមដូចជា ទំនុកចិត្ត របៀបរបប និង បណ្តាញផ្សេងៗ ដែលអាចបង្កើនប្រសិទ្ធភាពសង្គម ដោយជួយសំរួលដល់ សកម្មភាពមានការសំរបសំរួលល្អ" (១៩៩៣) ។ Putnam យល់ឃើញថា ប្រភពចំបងនៃទំនុកចិត្តក្នុងសង្គម គឺរបបបដិការ និងបណ្តាញនៃការចូលពាក់ព័ន្ធ ដែលអាចវាស់វែងបានតាមរយៈការចូលរួមរបស់ប្រជាជននៅក្នុងសមាគមនានា ។ ដង់ស៊ីតេនៃសមាគមបែបនេះ ដែលអាចវាស់វែងជាសំខាន់តាមរយៈអង្កេតបែបបរិមាណ វាបង្ហាញថាសង្គមណាមួយនោះមានមូលធនសង្គមធំទូលាយប៉ុណ្ណា ។

ការរិះគន់នាពេលថ្មីៗដល់វិធីសាស្ត្ររបស់ Putnam បានប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យច្រើន ហើយផ្តោតលើលទ្ធភាពរបស់ប្រជាជនដើម្បីប្រើប្រាស់ធនធានជាមូលធនសង្គម និងបរិបទដែលហ៊ុំព័ទ្ធបណ្តាញសង្គមនោះ (Grix 2001) ។ កត្តាផ្សេងៗដូចជា ការអប់រំ វត្តមានការងារ និង វណ្ណៈសង្គម វាសំខាន់បំផុតដើម្បីស្វែងយល់ពី លទ្ធភាពរបស់អ្នកណាម្នាក់ក្នុងការប្រើប្រាស់មូលធនសង្គម ដោយទទួលស្គាល់ថា ការចូលរួមនៅក្នុងសមាគម និងបណ្តាញផ្សេងៗ វាពឹងផ្អែកជាសំខាន់ទៅលើធនធាន និងឋានៈសង្គមរបស់អ្នកនោះ ។ ដូចគ្នាដែរ បរិបទសង្គមជាក់លាក់ណាមួយ វាកំនត់ពីទំរង់នៃមូលធនសង្គមដែលត្រូវផុសឡើង ហើយនិងទំនោរនៃលទ្ធភាពទទួលបានការប្រើប្រាស់មូលធនទាំងនោះ ។

លទ្ធភាពរបស់បុគ្គលណាមួយដើម្បីបានប្រើប្រាស់មូលធនសង្គម វាអាស្រ័យជាសំខាន់ទៅលើ ការរាប់បញ្ចូល រឺការផាត់ចេញបុគ្គលនោះនៅក្នុងសង្គម ។ ដោយមូលហេតុនេះ បណ្តាញសង្គមអាចបែងចែកជា ៣ប្រភេទសំខាន់ៗគឺ : ចំណងផ្សារភ្ជាប់ (bond) ស្ពានចំលង (bridge) និងចំណងទាក់ទង (link) (Woolcock 1998; Narayan 1999) ។ មូលធនសង្គមដែលជាចំណងផ្សារភ្ជាប់ រួមមានចំណងដ៏រឹងមាំតាមខ្សែផ្តេកជាមួយ សមាជិកគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង ដែលតែងជួយកាត់បន្ថយភាពងាយទទួលរងគ្រោះ និងផ្តល់នូវបណ្តាញសុវត្ថិភាពសង្គម ។ មូលធនសង្គមជាស្ពានចំលង រួមមានចំណងកិរិតខ្សោយតាមខ្សែផ្តេក ដែលតភ្ជាប់បុគ្គលនៅក្នុងក្រុម និងបណ្តាញផ្សេងៗទៅនឹងជនឯទៀត ដែលមានស្ថានភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។ ការតស្ពានចំលងជាមួយ មនុស្សនៅខាងក្នុង និងខាងក្រៅសហគមន៍ វាផ្តល់ឱកាសល្អៗសំរាប់ការកែលំអជីវភាព នឹងលទ្ធភាពធ្វើបំលាស់ទី ។ មូលធនសង្គមចំណងទាក់ទង គឺជាចំណងតាមខ្សែបញ្ឈរដែលតភ្ជាប់បុគ្គលទៅនឹង

* អាង សូផា ទទួលសញ្ញាប័ត្រអនុបណ្ឌិតពីវិទ្យាស្ថាន AIT (Asian Institute of Technology) និងធ្លាប់ធ្វើជាអ្នកសំរបសំរួលគំរោងវិភាគពីបញ្ហាអភិវឌ្ឍន៍ (ADI) របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នៅពេលកំពុងធ្វើការស្រាវជ្រាវ ។ អឿ អ៊ុល ទទួលសញ្ញាប័ត្រអនុបណ្ឌិតពីសាកលវិទ្យាល័យន័រតុន និងបានចូលជាសមាជិកក្រុម ADI តាំងពីឆ្នាំ១៩៩៩ ។ John McAndrew ទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតពីសាកលវិទ្យាល័យ Amsterdam និងបានធ្វើជាទីប្រឹក្សានៃគំរោង ADI តាំងពីឆ្នាំ២០០៣ ។

*តារាង ១. គ្រួសារធ្លាប់រងគ្រោះដោយទឹកជំនន់ធ្ងន់ធ្ងរ រឺធម្មតា ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥, នៅភូមិ អំពិល, ជ័យ និងស្លែងខ្ពស់ ក្នុងឃុំសានគរ ហើយនិងភូមិសង្គម និងវល្លិយាវ ក្នុងឃុំដំរីស្លាប់ ( មិថុនា ២០០៥)*

| ឆ្នាំ | ទឹកជំនន់ធ្ងន់ធ្ងរ | | ទឹកជំនន់ធម្មតា | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| 2004/05 | 3 | 2 | 102 | 66 |
| 2003/04 | 9 | 6 | 105 | 68 |
| 2002/03 | 58 | 37 | 70 | 45 |
| 2001/02 | 134 | 86 | 18 | 12 |
| 2000/01 | 147 | 95 | 5 | 3 |
| N=155 | | | | |

អ្នកមានអំនាច/ឥទ្ធិពល ដូចជា ធនាគារ ស្ថាប័នរដ្ឋ និងមន្ត្រីជាប់ឆ្នោត ។ ចំណងទាក់ទងជាមួយបុគ្គល និងស្ថាប័នដ៏មានអំនាច ជួយឱ្យបុគ្គលអាចប្រើប្រាស់ធនធានបានកាន់តែសក្តិសិទ្ធិ ដើម្បីទាញយកផលប្រយោជន៍ក្នុងរយៈពេលវែង ។ មនុស្សដែលមានបណ្តាញរឹងមាំនៅក្នុងប្រភេទណាមួយ រឺគ្របដណ្តប់លើប្រភេទទាំងបី តែងតែមានសមត្ថភាពល្អប្រសើរ ដើម្បីប្រឈមមុខនឹងគ្រោះមហន្តរាយ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម ។

## បទពិសោធន៍នៃទឹកជំនន់[២]

គ្រួសារដែលត្រូវបានចុះអង្កេតនៅឃុំសានគរ ក្នុង ៣ភូមិ គឺ អំពិល ជ័យ និងស្លែងខ្ពស់ ធ្លាប់រងគ្រោះដោយសារទឹកជំនន់ដ៏ធ្ងន់ធ្ងរចំនួន ៥ឆ្នាំ ពីឆ្នាំ ២០០០/០១ ដល់ ២០០៤/០៥ (តារាង១) ។ ពួកគេភាគច្រើនបានរងគ្រោះដោយទឹកជំនន់កាលពីឆ្នាំ ២០០០/០១ និង ២០០១/០២ ហើយជាង ១/៣ បានរងគ្រោះដោយទឹកជំនន់នៅឆ្នាំ២០០២/០៣ ។ គ្រួសារឆ្លើយសំភាសន៍ជាង ១/៤ រាយការណ៍ថា ពួកគេត្រូវជម្លៀសចេញពីលំនៅដ្ឋានដោយសារតែទឹកជំនន់ ។ ពួកគេ ៩០% មានសមាជិក គ្រួសារធ្លាក់ខ្លួនឈឺដែលភាគច្រើនជាជំងឺរាគរូស និងចុកពោះ ។ ទឹកជំនន់ធ្ងន់ធ្ងរច្រើនឆ្នាំជាប់ៗគ្នា ធ្វើឱ្យខូចខាតយ៉ាងខ្លាំងដល់ចំណូលពីកសិកម្ម និងរារាំងអ្នកភូមិមិនឱ្យរើខ្លួនបានឆាប់ឡើងវិញ ។ ជំនួយពីបណ្តាស្ថាប័នខាងក្រៅ មានប្រយោជន៍ណាស់ ប៉ុន្តែមិនគ្រប់គ្រាន់ ដូច្នេះគ្រួសារនានាត្រូវតែពឹងផ្អែកជាសំខាន់លើធនធានផ្ទាល់ខ្លួនដើម្បីស្តារជីវភាព ។ ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង និងមិត្តភក្តិ ផុសផុលខ្លាំងណាស់នៅពេលទឹកជំនន់មកដល់ភ្លាម ប៉ុន្តែត្រូវថយចុះដោយសារភាពក្រីក្ររបស់អ្នកភូមិ ។ គួរកត់សំគាល់ថា គ្រួសារអ្នកឆ្លើយសំភាសន៍ក្នុង ២ភូមិ នៅឃុំដំរីស្លាប់ ដែលស្ថិតនៅខាងក្រៅតំបន់ទំនាបលិចទឹកបឹងទន្លេសាប មិនបានរងគ្រោះដោយសារទឹកជំនន់ទេក្នុងប៉ុន្មានឆ្នាំនោះ ។

## បទពិសោធន៍នៃគ្រោះរាំងស្ងួត

គ្រួសារដែលយើងបានចុះអង្កេតក្នុងឃុំទាំង២ គឺធ្លាប់រងគ្រោះដោយការរាំងស្ងួតធ្ងន់ធ្ងរ ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ (តារាង២) ។ លើកលែងតែការដាំដុះក្នុងឆ្នាំ២០០២/០៣ ភូមិអង្កេតទាំង៣ នៅឃុំសានគរ បានជួបការរាំងស្ងួតប្រចាំឆ្នាំធ្ងន់ធ្ងរជាង ២ភូមិទៀត នៅឃុំដំរីស្លាប់ ក្នុងរយៈពេល ៥ឆ្នាំនៃការសិក្សា ។ ចំណុចនេះគួរកត់សំគាល់ណាស់ ពីព្រោះក្នុងអំឡុងពេលដូចគ្នា ភូមិនានានៅឃុំសានគរ ក៏បានជួបនឹងទឹកជំនន់ធ្ងន់ធ្ងរដែរ ។ ក្នុងបញ្ហាសុខភាព គេឃើញមានដូចមុននូវ ជំងឺរាគរូស ចុកពោះ និងការខាតបង់ចំណូលដោយសារការខូចសំណាបនិងផលស្រូវ ប៉ុន្តែនៅឃុំដំរីស្លាប់ វាធ្ងន់ធ្ងរជាងបន្តិច ។ រឿងនេះ ក៏អាចមកពីនៅឃុំដំរីស្លាប់ មានចំនួនភាគរយច្រើនជាងនៃ គ្រួសារដែលបានទទួលជំនួយក្នុងពេលមានការរាំងស្ងួតខ្លាំង ។ តាមធម្មតានៅពេលមានការរាំងស្ងួតធ្ងន់ធ្ងរ គេមិនសូវមើលឃើញថាមានតំរូវការច្រើន ដូចនៅពេលមានទឹកជំនន់ធ្ងន់ធ្ងរទេ ។

*តារាង ២. គ្រួសារធ្លាប់រងគ្រោះដោយការរាំងស្ងួតធ្ងន់ធ្ងរ រឺ ធម្មតា នៅឆ្នាំ ២០០០/០១ ដល់ ២០០៤/០៥ ( មិថុនា ២០០៥)*

| ឆ្នាំ | ភូមិអំពិល ជ័យ និងស្លែងខ្ពស់ ក្នុងឃុំសានគរ | | | | ភូមិសង្គម និងវល្លិយាវ ក្នុងឃុំដំរីស្លាប់ | | | |
|---|---|---|---|---|---|---|---|---|
| | រាំងស្ងួតធ្ងន់ធ្ងរ | | រាំងស្ងួតធម្មតា | | រាំងស្ងួតធ្ងន់ធ្ងរ | | រាំងស្ងួតធម្មតា | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| 2004/05 | 67 | 43 | 66 | 43 | 7 | 7 | 69 | 69 |
| 2003/04 | 92 | 59 | 55 | 35 | 41 | 41 | 53 | 53 |
| 2002/03 | 67 | 43 | 73 | 47 | 76 | 76 | 21 | 21 |
| 2001/02 | 42 | 27 | 66 | 43 | 19 | 19 | 72 | 72 |
| 2000/01 | 34 | 22 | 65 | 42 | 9 | 9 | 67 | 67 |
| | N= 155 | | | | N=100 | | | |

*តារាង ៣. ផលស្រូវមធ្យមតាមគ្រួសារ ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ នៅភូមិអំពិល ជ័យ និងស្លែងខ្ពស់ ក្នុងឃុំសានគរ ( មិថុនា ២០០៥)*

| ឆ្នាំ | ផលស្រូវវស្សាមធ្យម (គ.ក្រ) | ផលស្រូវប្រាំងមធ្យម (គ.ក្រ) | ផលស្រូវសរុបមធ្យម (គ.ក្រ) |
|---|---|---|---|
| 2004/05* | 696 | 166 | 693 |
| 2003/04** | 410 | 180 | 406 |
| 2002/03*** | 328 | 0 | 325 |
| 2001/02**** | 207 | 480 | 210 |
| 2000/01***** | 120 | 480 | 124 |

*N = 125 សំរាប់រដូវវស្សា, 6 សំរាប់រដូវប្រាំង, 127 សំរាប់សរុប
**N = 102 សំរាប់រដូវវស្សា, 2 សំរាប់រដូវប្រាំង, 104 សំរាប់សរុប
***N = 88 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 89 សំរាប់សរុប
****N = 79 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 80 សំរាប់សរុប
*****N = 80 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 81 សំរាប់សរុប

## ទិន្នផលស្រូវពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥

ភូមិសិក្សាទាំង៣ នៅឃុំសានគរ និងភូមិទាំង២ នៅឃុំដីរស្លាប់ មានការពឹងផ្អែកយ៉ាងខ្លាំងលើផលស្រូវវស្សា ។ ដោយសារមានទឹកជំនន់ និងការរាំងស្ងួតធ្ងន់ធ្ងរ ភូមិនានាក្នុងឃុំទាំងពីរ មានផលស្រូវទាបខ្លាំងណាស់ក្នុងបណ្ដាឆ្នាំមានគ្រោះធម្មជាតិដែលបានសិក្សា (តារាង ៣ និង ៤) ។ ដោយសារស្ថានភាពដី ផលស្រូវនៅភូមិនានាក្នុងឃុំសានគរ បានចុះទាបបំផុតនៅពេលមានទឹកជំនន់ប៉ះពាល់ខ្លាំងបំផុត រីឯផលស្រូវនៅភូមិនានាក្នុងឃុំដីរស្លាប់ បានចុះទាបបំផុតនៅពេលមានការរាំងស្ងួតប៉ះពាល់ខ្លាំងបំផុត ។ ទោះបីនៅក្នុងឆ្នាំដែលបានផលល្អបំផុត និងទោះបីស្ថិតក្នុងតំបន់អេកូឡូស៊ីពីរខុសគ្នាក្ដី ក៏ទិន្នផលក្នុងឃុំទាំង២ ទាបជាង ០,៥តោន/ហិកតា (ក្នុង ៥ឆ្នាំសិក្សា មាន ៣ឆ្នាំដែលឃុំដីរស្លាប់ទទួលបានលើសពី ០,៥តោន/ហិកតា រីឯនៅឃុំសានគរមាន ១ឆ្នាំប៉ុណ្ណោះ) ។ កង្វះខាតស្រូវដែលឃើញមានជាធម្មតាទៅហើយនៅតាមឆ្នាំដូចធម្មតា វាក៏កើនថែមទៀតក្នុងអំឡុងពេលមានគ្រោះធម្មជាតិ ហើយវាបានកាត់បន្ថយការហូបចុករបស់គ្រួសារមួយភាគធំ ។

ការលក់ រឺបញ្ចាំដីស្រែ ច្រើនតែជាលទ្ធផលនៃទឹកជំនន់ និងការរាំងស្ងួតធ្ងន់ធ្ងរ ។ ការបាត់បង់ដីស្រែធ្វើឱ្យគ្រួសារកសិករដែលរកបានតែមួយរស់ៗពិបាករើខ្លួនឱ្យបានទាំងស្រុងពីផលអាក្រក់ផ្សេងៗនៃគ្រោះធម្មជាតិ ហើយក៏ត្រូវបន្ថយការធ្វើស្រែ ធ្វើជាសកម្មភាពរកចិញ្ចឹមជីវិតចំបងរបស់ខ្លួនទៀត ។ គ្រួសារដែលពុំមានដីគ្រប់គ្រាន់សំរាប់ធ្វើស្រែ និងដាក់ធានាខ្ចីប្រាក់ច្រើនតែត្រូវដាច់ឆ្ងាយពីគេថែមទៀត ដោយសារគ្រោះទឹកជំនន់ និងការរាំងស្ងួត ។ ការរានព្រៃយកដីធ្វើស្រែ គឺជាដំណោះស្រាយសំរាប់អ្នកភូមិជាច្រើនក្នុងឃុំទាំងពីរ ដើម្បីពង្រីកដីកាន់កាប់ ថ្វីបើវិធីនេះបានធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិដែលមានសារៈសំខាន់សំរាប់ការគ្រប់គ្រងទឹក ។

## ការផ្លាស់ប្ដូរជីវភាព

គ្រោះរាំងស្ងួតនិងទឹកជំនន់ដ៏ធ្ងន់ធ្ងរ ដែលកើតមានឡើងនៅតំបន់សិក្សាពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ បាននាំអោយមានដំណើរផ្លាស់ប្ដូរដ៏ធំទូលាយក្នុងសង្គមនៅក្នុងតំបន់បឹងទន្លេសាប និងតំបន់ឯទៀតនៅជនបទកម្ពុជា ។ ផលស្រូវក្នុងរយៈ ៥ឆ្នាំនៃគ្រោះធម្មជាតិបន្តបន្ទាប់គ្នា បានធ្លាក់ចុះទាបបំផុត ហើយបង្ខំអោយគ្រួសារជាច្រើនក្នុងភូមិទាំង ៥ ត្រូវពឹងផ្អែកទៅលើរបរចិញ្ចឹមជីវិតក្រៅពីធ្វើស្រែវស្សា ដូចជា ការនេសាទ ការប្រមូលធនធានព្រៃឈើ និងចំណាកស្រុកទៅធ្វើការងារស៊ីប្រាក់ឈ្នួល ។ ដើម្បីប៉ះប៉ូវការខូចខាតផលស្រូវ គ្រួសារនានានៅឃុំសានគរ ក្នុងតំបន់វាលលិចទឹកបឹងទន្លេសាប បានទាញយកផលពីធនធានត្រីនៅក្នុងបឹង រីឯគ្រួសារនៅឃុំដីរស្លាប់បានកាប់ឈើ និងធ្វើឡធ្យូង ។ ការផ្លាស់ប្ដូរភ្លាមៗមកប្រើប្រាស់ប្រភពចំណូលពីធនធានទាំងនេះ បានរួមចំណែកធ្វើឱ្យថយចុះធនធានធម្មជាតិ ។

ក្នុងពេលជាមួយគ្នា គ្រួសារជាច្រើននៅឃុំទាំង២ បានពឹងផ្អែកកាន់តែខ្លាំងទៅលើចំណាកស្រុក ទៅធ្វើពលកម្មស៊ីប្រាក់ឈ្នួលដើម្បីទ្រទ្រង់ជីវភាព ។

*តារាង ៤. ផលស្រូវមធ្យមតាមគ្រួសារ ពីឆ្នាំ២០០០/០១ ដល់ ២០០៤/០៥ នៅភូមិសង្គម និងវល្លិយាវ ក្នុងឃុំដីរស្លាប់ ( មិថុនា ២០០៥)*

| ឆ្នាំ | ផលស្រូវវស្សាមធ្យម (គ.ក្រ) | ផលស្រូវប្រាំងមធ្យម (គ.ក្រ) | ផលស្រូវសរុបមធ្យម (គ.ក្រ) |
|---|---|---|---|
| 2004/5* | 553 | 432 | 595 |
| 2003/4** | 353 | 216 | 363 |
| 2002/3*** | 365 | 97 | 367 |
| 2001/2**** | 582 | --- | 582 |
| 2000/1***** | 691 | --- | 691 |

*N = 91 សំរាប់រដូវវស្សា, 9 សំរាប់រដូវប្រាំង, 91 សំរាប់សរុប
**N = 89 សំរាប់រដូវវស្សា, 4 សំរាប់រដូវប្រាំង, 89 សំរាប់សរុប
***N = 82 សំរាប់រដូវវស្សា, 1 សំរាប់រដូវប្រាំង, 82 សំរាប់សរុប
****N = 77 សំរាប់រដូវវស្សា, --- សំរាប់រដូវប្រាំង, 77 សំរាប់សរុប
*****N = 72 សំរាប់រដូវវស្សា, --- សំរាប់រដូវប្រាំង, 72 សំរាប់សរុប

ក្នុងរយៈ ៥ឆ្នាំក្រោមការសិក្សា ជិត ៦០% នៃសមាជិកគ្រួសារមកពីឃុំសានគរ និងប្រហែល ៥០% នៃគ្រួសារមកពីឃុំដរីស្លាប់ បានចាកចេញពីភូមិទៅរកចំណូល ជាពិសេសធ្វើជាអ្នកស៊ីឈ្នួលធ្វើស្រែចំការនៅថៃ និងធ្វើកម្មកររោងចក្រកាត់ដេរនៅភ្នំពេញ ។ ការងារចំណាកស្រុកដែលកាលពីមុនគ្រាន់តែផ្ដល់ចំណូលបន្ថែមសំរាប់រយៈពេលខ្លី វាបានក្លាយជាយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតចំបងគេសំរាប់គ្រួសារជាច្រើន ។

ដោយមិនអាចពឹងផ្អែកលើផលិតកម្មស្រូវ ហើយការងារក្រៅកសិដ្ឋាន ក៏មានតិច គ្រួសារជាច្រើន ត្រូវខ្ចីបុលក្នុងអត្រាការប្រាក់ខ្ពស់ហួសហេតុ ដើម្បីទ្រទ្រង់ជីវិតប្រចាំថ្ងៃ ។ គ្រួសារជាច្រើនក៏ត្រូវខ្ចីប្រាក់ច្រើនៗ ក្នុងអត្រាការប្រាក់ដ៏ខ្ពស់ ដើម្បីដោះស្រាយចំណាយព្យាបាលជំងឺ ។ គ្រួសារមួយចំនួនបានលក់ រឺបញ្ចាំដីស្រែ ដើម្បីបានប្រាក់ រឺសងបំណុលគេ ហើយក៏ធ្វើអោយថយចុះដល់សមត្ថភាពរបស់ខ្លួន ក្នុងការធ្វើស្រែជាសំខាន់ ដើម្បីទ្រទ្រង់ជីវភាព ។ តាមការក្រឡេកមើលទៅក្រោយវិញ គ្រោះធម្មជាតិដែលចាប់ផ្ដើមដោយ ទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅឆ្នាំ ២០០០/០១ បានធ្វើគ្រួសារជាច្រើនប្រែប្រួលជីវភាព។

## ការពឹងផ្អែកលើបណ្ដាញមូលធនសង្គម

ក្នុងការប្រឈមនឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនេះ យើងបានធ្វើសំភាសន៍អ្នកផ្ដល់ព័តិមានគន្លឹះ និងធ្វើអង្កេត ដោយប្រឹងពិនិត្យមើលពីផលប្រយោជន៍នៃមូលធនសង្គម ។ នៅពេលមានទឹកជំនន់ មូលធនសង្គមដែលជាចំណងផ្សារភ្ជាប់ និងស្ពានចំលង បានស្ដែងចេញយ៉ាងច្បាស់ ។ បណ្ដាគ្រួសារនៅតាមភូមិក្នុងឃុំសានគរ បានជួយគ្នាទៅវិញទៅមក ដើម្បីជំលៀសសមាជិកគ្រួសារ មើលថែសត្វចិញ្ចឹម ដើរល្បាតការពារផ្ទះក្នុងភូមិ ដឹកកុមារទៅរៀន ចែកចាយទឹកស្អាត និងផ្ដល់កំចីតូចៗជាស្រូវអង្ករឱ្យគ្នា ។ នៅពេលទឹកស្រកទៅវិញ គ្រួសារនានានៅឃុំសានគរ បានរួបរួមគ្នាជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ ដូចជា ប្រឡាយទឹក ទ្វារទឹក លូទឹក ផ្លូវ សាលារៀន ជាដើម ។ ជារឿយៗ មានស្ថាប័នខាងក្រៅបានមកជួយដល់ការប្រឹងប្រែងស្ដារកសាងឡើងវិញទាំងនេះ ។

នៅពេលមានគ្រោះរាំងស្ងួត បណ្ដាញមូលធនសង្គមជាចំណងផ្សារភ្ជាប់ និងជាស្ពានចំលង (ដែលតែងតូចជាងចំណងផ្សារភ្ជាប់) ក៏ស្ដែងចេញយ៉ាងច្បាស់ដែរ ប៉ុន្ដែមិនសូវលេចធ្លោដូចក្នុងសកម្មភាពដ៏មមាញឹក នៅពេលមានទឹកជំនន់ទេ ។ ក្នុងពេលមានគ្រោះរាំងស្ងួត សាច់ញាតិ និងអ្នកជិតខាងនៅតាមភូមិនានា តែងជួយគ្នាទៅវិញទៅមកដើម្បីបំពេញស្ដុកពូជស្រូវឡើងវិញ ដោយផ្ដល់ប្រាក់កំចីតូចៗ ជួយធានាកំចីពីអ្នកចងការប្រាក់ ជួយមើលថែអ្នកជំងឺ អនុញ្ញាតអោយប្រើប្រាស់អណ្ដូងគ្រួសារ និង ជួយក្រុមអ្នកងាយរងគ្រោះ ។ ក្រោយពេលមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរ មូលធនសង្គមជាស្ពានចំលងតែងស្ដែងចេញជាគ្រួសារនានាចូលធ្វើការរួមគ្នា នៅក្នុងគំរោងស្បៀងពលកម្មបំរើសហគមន៍ ដែលឧបត្ថម្ភដោយអង្គការពីខាងក្រៅ ។

ដូចគ្នាដែរ បណ្ដាញមូលធនសង្គមជាស្ពានចំលង បានជួយគ្រួសារនានានៅឃុំទាំងពីរ ប្រឈមមុខដោះស្រាយតំរូវការដ៏ច្រើននៃការផ្លាស់ប្ដូរសង្គមដែលកើតមានឡើងក្នុងដំណើរជីវិតរបស់ពួកគាត់ ។ ពលករចំណាកស្រុកចេញពីភូមិទាំងពីរ អាចរកបានការងារធ្វើនៅភ្នំពេញ រឺនៅថៃ ឆ្លងតាមខ្សែរយៈទំនាក់ទំនងជាមួយសាច់ញាតិ មិត្តភក្ដិ អ្នកជិតខាង និងភ្នាក់ងារជ្រើសរើសពលករ ។ បុរស/នារីវ័យក្មេង មកពីបណ្ដាភូមិក្នុងឃុំសានគរ បានប្រើប្រាស់អ្នកស្គាល់គ្នាជាមួយម្ចាស់ឡូត៍នេសាទនៅបឹងទន្លេសាប ដើម្បីបានការងារជាកម្មករស៊ីឈ្នួល ។ គ្រួសារនៅឃុំទាំងពីរ ទទួលបានប្រាក់ពីអ្នកចងការប្រាក់នៅឯផ្សារឃុំសានគរ ដើម្បីបណ្ដាក់ទុនឡើងវិញ ទៅលើផលិតកម្មស្រូវដែលងាយខូចខាតដោយគ្រោះធម្មជាតិ ទោះបីអត្រាការប្រាក់វាខ្ពស់ហួសហេតុ ហើយដំណាំស្រូវក៏ផ្សងព្រេងច្រើនក៏ដោយ ។ គ្រួសារនៅឃុំដរីស្លាប់ ក៏ពឹងផ្អែកដូចគ្នាលើអ្នកចងការប្រាក់ ដើម្បីដោះស្រាយតំរូវការបង់ប្រាក់ក្រៅផ្លូវការ ទៅអោយភ្នាក់ងាររដ្ឋ ដើម្បីបានការអនុញ្ញាតឱ្យចូលកាប់ឈើ និងដឹកឈើហ៊ុបចេញពីខេត្តព្រះវិហារ ។

តាមគំនិតលោក Robert Putnam អត្រាខ្ពស់នៃសមាជិកភាព និងការចូលរួមនៅក្នុងសមាគមផ្សេងៗ គឺជាសូចនាករមួយសំខាន់បំផុតដែលបង្ហាញពីទំហំមូលធនសង្គមនៅក្នុងសង្គម ។ នៅតាមភូមិក្នុងឃុំសានគរ និងឃុំដរីស្លាប់ ការចូលរួមរបស់គ្រួសារ និងអត្រាសមាជិកភាពនៅតាមក្រុមនានាក្នុងសហគមន៍ បានកើនខ្លាំងណាស់ ចាប់ពីឆ្នាំ២០០០ ដល់ ២០០៥ ។ យោងតាមលោក Putnam កំណើននេះបង្ហាញពីមូលធនសង្គមដ៏ច្រើន និងការរួបរួមគ្នាល្អនៅក្នុងភូមិ ។ បើមិនដូច្នោះទេ អ្នករិះគន់វិធីសាស្ត្ររបស់លោក Putnam គឺជាអ្នកនិយាយត្រូវ ។ ការស៊ើបអង្កេតដ៏ល្អមួយបែបទៀត បំបែរការស្រាវជ្រាវទៅផ្ដោតលើលទ្ធភាពបានប្រើប្រាស់ស្ដុកនៃមូលធនសង្គម នៅក្នុងស្ថានភាពជាក់ស្ដែងនៃសង្គមនីមួយៗ ។ សំរាប់ឃុំសានគរ និងឃុំដរីស្លាប់ គេមើលឃើញច្បាស់ថា គ្រួសារនានាមានលទ្ធភាពប្រើប្រាស់មូលធនសង្គមជាចំណងផ្សារភ្ជាប់ និងមូលធនសង្គមជាស្ពានចំលងក៏ពិតមែន ប៉ុន្ដែពួកគាត់សឹងតែត្រូវផាត់ចេញទាំងស្រុងពីមូលធនសង្គមជាចំណងទាក់ទង ។ ជាទូទៅ គ្រួសារអ្នកឆ្លើយសំភាសន៍ តែងខ្វះចំណងទាក់ទងតាមខ្សែបញ្ឈរជាមួយនឹងបុគ្គល/ស្ថាប័នមានអំណាច ដែលអាចអនុញ្ញាត អោយពួកគាត់អាចប្រើប្រាស់ធនធានបានយ៉ាងសក្ដិសិទ្ធិដើម្បីទាញយកផលប្រយោជន៍ក្នុងរយៈពេលវែង ។

សរុបមក បញ្ហាចំបងគេដែលគ្រួសារនានានៅឃុំសានគរ និងឃុំដរីស្លាប់ត្រូវប្រឈមមុខ គឺការពង្រឹង និងពង្រីកបណ្ដាញមូលធនសង្គមដែលជាចំណងផ្សារភ្ជាប់ និងជាស្ពានចំលងរបស់ខ្លួន អោយវាតភ្ជាប់ទៅនឹងបណ្ដាញមូលធនសង្គមជាចំណងទាក់ទងនានា មានទាំងចំណងទាក់ទងជាមួយស្ថាប័នរដ្ឋផង ។ ដូចគ្នាដែរ បញ្ហាប្រឈមរបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត គឺក្រៅពីការកសាងសមត្ថភាពរបស់សហគមន៍ក្នុងការគ្រប់គ្រងគ្រោះមហន្ដរាយ គេត្រូវជួយសំរួលអោយអ្នកភូមិមានលទ្ធភាពប្រើប្រាស់ស្ដុកមូលធនសង្គមជាចំណងទាក់ទង ដើម្បីអោយពួកគាត់អាចប្រើប្រាស់បាននូវធនធានដែលបច្ចុប្បន្នគេផាត់គាត់ចេញ និងអោយពួកគាត់មានសំលេងនៅក្នុងសេចក្ដីសំរេចផ្សេងៗ ដែលអាចប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគាត់។

## កំណត់សំគាល់

១. វិធីសាស្ត្រស្រដៀងគ្នា ត្រូវបានដាក់ចូលយ៉ាងស៊ីជម្រៅនៅក្នុង FitzGerald and So 2007 ។

២. ទិន្នន័យ និងតារាង ដូចមានបង្ហាញនៅតាមផ្នែកដូចតទៅ បានមកពីការសិក្សារបស់ CCC ស្ដីពីការស្វែងយល់ពីតួនាទីមូលធនសង្គម នៅពេលមានទឹកជំនន់ និងគ្រោះរាំងស្ងួតៈ ការសិក្សានៅ ៥ភូមិ ក្នុង ២តំបន់អេកូឡូស៊ីនៅខេត្តកំពង់ធំ (ក្រុមវិភាគបញ្ហាអភិវឌ្ឍន៍ និងអ្នកចូលរួមស្រាវជ្រាវ ខែសីហា ២០០៧) ។

## ឯកសារយោង

*សូមមើលឯកសារយោងក្នុងអត្ថបទភាសាអង់គ្លេស*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ផ្នែកនេះផ្តោតលើសេដ្ឋកិច្ចធំបង១ក្នុងពិភពលោក និងសេដ្ឋកិច្ចភាគច្រើននៅអាស៊ីខាងកើត ។ ស្ថានភាពសេដ្ឋកិច្ចនៅបណ្តាប្រទេសទាំងនោះមានលក្ខណៈទាក់ទងជាពិសេសទៅនឹងសេដ្ឋកិច្ចកម្ពុជា ។

នៅត្រីមាសទី២ឆ្នាំ២០០៧ ផសស ពិតនៅ US កើន ១,៩ % ខ្ពស់ជាងមួយឆ្នាំមុន ធៀបនឹងកំណើន ១,៥% នៅត្រីមាសមុន ។ រឿងនេះបណ្តាលមកពីការធ្លាក់ចុះការនាំចូល កំណើនចំណាយរដ្ឋាភិបាលសម្ព័ន្ធ និងវិនិយោគលើទំនិញឯកជន ព្រមទាំង កំណើនការនាំចេញ សំណង់មិនមែនសំរាប់ស្នាក់នៅ និងគ្រឿងបរិក្ខា និងសូហ្វវែរ ។

ផសស ពិត នៅតំបន់អឺរ៉ូ កើន ២,៥% នៅត្រីមាសទី២ ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន និងកើន ០,៣% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅជប៉ុន កើន ២,៣% ធៀបនឹងមួយឆ្នាំមុន និងកើន ០,១% ធៀបនឹងត្រីមាសមុន ។

សេដ្ឋកិច្ចចិន មានកំណើន ១១,៥% នៅត្រីមាសទី២ ខ្ពស់ជាងមួយឆ្នាំមុន ។ កំណើននេះនាំមុខដោយឧស្សាហកម្ម ដែលមានតំលៃបន្ថែមកើន ១៣,៦% ធៀបនឹងកំណើន ១០,៦% ក្នុងវិស័យសេវាកម្ម និង ៤,០% ក្នុងវិស័យកសិកម្ម ។ ផសស ពិត នៅកូរ៉េខាងត្បូង កើន ៤,៥% ធៀបនឹងមួយឆ្នាំមុន និងកើន ១,៨% ធៀបនឹងត្រីមាសមុន ។ សំរាប់ផ្នែកផលិតកម្ម ឧស្សាហកម្មផលិត និង សេវាកម្ម បានកើនឡើង រីឯការសាងសង់ធ្លាក់ចុះ ។ សំរាប់ផ្នែកចំណាយ ចំណាយប្រើប្រាស់ឯកជន មានសភាពប្រសើរឡើងជាបណ្តើរ១ ស្របពេលដែលវិនិយោគលើគ្រឿងសំរួលការ និងការនាំចេញ បន្តលូតលាស់ខ្លាំង ។ ផសស ពិត នៅតៃវ៉ាន់ និង ហុងកុង មានកំណើន ៥,០៧% និង ៦,៩% ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន។

សេដ្ឋកិច្ចម៉ាឡេស៊ី មានកំណើន ៥,៧% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី២ ឆ្នាំ២០០៧ ។ កំណើននៅត្រីមាសនេះ បានជំរុញខ្លាំងដោយ វិស័យសេវាកម្ម (៩,២%) រ៉ែ (៧,៧%) និង សំណង់ (៤,៨%) ។ សេដ្ឋកិច្ចនៅសិង្ហបុរី កើន ៨,២% ក្នុងរយៈ១២ខែប៉ុណ្ណោះ ។ ឧស្សាហកម្មផលិត និង សំណង់មានកំណើនខ្លាំងដល់ ១០,២% និង ១៧,៩% រីឯ សេវាកម្មមានកំណើនមធ្យម ៧,០% ។ ផសស ពិតនៅថៃ កើន ៤,៤% ខ្ពស់ជាងត្រីមាសទី២ ឆ្នាំ២០០៦ ។ វិស័យកសិកម្ម កើន ៩,៧% ខ្ពស់ជាងត្រីមាសមុន (៣,៣%) ដែលបណ្តាលជាសំខាន់មកពីកំណើនផលដំណាំ និង ត្រី ។ វិស័យមិនមែនកសិកម្ម កើន ៤,០% ធៀបនឹងកំណើន ៤,៣% នៅត្រីមាសមុន។

## អតិផរណាពិភពលោក និង អត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី២ ឆ្នាំ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅUS កើនតាមអត្រាប្រចាំឆ្នាំ ២,៧% ធៀបនឹង ២,៤% នៅត្រីមាសទី១ ។ រឿងនេះបណ្តាលមកពីកំណើនថ្លៃម្ហូបអាហារ ថ្នាំពេទ្យ ផ្ទះស្នាក់នៅ និងថាមពល ។ នៅតំបន់អឺរ៉ូ មានអតិផរណា ១,៩% គឺគ្មានប្រែប្រួលពីត្រីមាសមុនទេ ។ កំណើនថ្លៃទំនិញក្នុងរយៈ១ឆ្នាំនេះ បណ្តាលមកពីកំណើនអាករលើតំលៃបន្ថែមនៅអាឡឺម៉ង់ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់ធ្លាក់ចុះ ០,១% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី២ ។ នេះបណ្តាលមកពីការធ្លាក់ថ្លៃកញ្ចប់ខ្សែទស្សនកិច្ចទៅក្រៅប្រទេស និងឧបករណ៍អេឡិចត្រូនិកសំរាប់ប្រើប្រាស់ក្នុងផ្ទះ ។ ប៉ុន្តែបំរែបំរួលនេះ វាតិចតួចសឹងស្មើសូន្យ បើសិនមិនរាប់បញ្ចូលនូវផលិតផលប្រេងកាត និងកត្តាពិសេស១ផ្សេងទៀត។

នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ដុល្លារUS ប្រែប្រួលមិនទៀងទាត់ ទល់នឹងរូបិយវត្ថុដទៃទៀត ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១២០,៨យ៉េន/ដុល្លារUS ធៀបនឹង ១១៩,៤យ៉េន/ដុល្លារUS នៅត្រីមាសមុន ។ ការឡើងថ្លៃប្រាក់ដុល្លារទល់នឹងប្រាក់យ៉េនជប៉ុន បណ្តាលមកពីគំលាតកាន់តែធំនៃអត្រាការប្រាក់ ។ ទល់នឹងប្រាក់អឺរ៉ូ ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដុល្លារUS ប្តូរបាន ០,៧៤អឺរ៉ូ/ដុល្លារUS ៧,៦៨យ៉ុន/ដុល្លារUS និង ៩២៩វ៉ុន/ដុល្លារUS គឺធ្លាក់ថ្លៃ បើធៀបនឹងអត្រា ០,៧៦អឺរ៉ូ/ដុល្លារUS ៧,៧៦យ៉ុន/ដុល្លារUS និង ៩៣៩វ៉ុន/ដុល្លារUS នៅត្រីមាសទី១ ២០០៧ ។ ការធ្លាក់ថ្លៃដុល្លារUS គឺដោយសារអ្នកចូលរួមទីផ្សារ ធ្វើការវាយតំលៃថា ទៅអនាគតតំបន់អឺរ៉ូ ប្រទេសចិន និងប្រទេសកូរ៉េខាងត្បូង មានលក្ខណៈអំណោយផលជាង ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី២ ប្រេងឆា សណ្តែកសៀង ប្រេងឆៅ សាំង និង មាស៊ូតឡើងថ្លៃ រីឯ ពោត និង អង្ករធ្លាក់ថ្លៃ ។ ប្រេងឆាលក់បាន ៦៩១,៤៤ដុល្លារ/តោន ធៀបនឹង ៥៥២,០៦ដុល្លារ/តោន នៅត្រីមាសទី១ រីឯពោតលក់បាន ១៤៦,១០ដុល្លារ/តោន និង សណ្តែកសៀង ២៥៩,៩៥ ដុល្លារ/តោន ។ អង្ករ Thai 100% B លេខ២ នៅទីផ្សារបាងកក លក់ថ្លៃ ២៨៣,៨៩ដុល្លារ/តោន ធៀបនឹង ២៩៤,១៧ដុល្លារ/តោន នៅត្រីមាសមុន ។ ប្រេងឆៅ ឡើងថ្លៃ

*តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | 2007 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | 13.4 | 10.6 | - | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 5.5 | 6.1 | - | - |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.2 | 5.9 | 5.8 | 5.7 | 5.3 | 5.7 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 7.1 | 7.0 | 6.0 | 8.2 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 4.5 | 4.8 | 4.7 | 4.2 | 4.3 | 4.4 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | 8.4 | 8.1 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 10.4 | 10.7 | 11.1 | 11.5 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 6.8 | 7.0 | 5.6 | 6.9 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 4.7 | 5.0 | 4.8 | 5.0 | 4.0 | 4.5 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 5.0 | 4.0 | 4.1 | 5.07 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 2.6 | 3.3 | 3.0 | 2.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.7 | 2.3 | 2.2 | 2.3 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.3 | 3.1 | 1.5 | 1.9 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

២១% ធៀបនឹងត្រីមាសមុន ដល់ ៦៥,៤១ដុល្លារ/ធុង ។ សាំង និង ម៉ាស៊ូត ឡើងថ្លៃ គួរអោយចាប់អារម្មណ៍ ធៀបនឹងត្រីមាសមុន ដោយសាំង ឡើងថ្លៃ ៣៩% និង ម៉ាស៊ូត ១៨% ។ សាំង លក់បាន ៥៧,៩៣សេន/លីត្រ និង ម៉ាស៊ូត លក់បាន ៥៣,៩០សេន/លីត្រ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភីម រុនស៊ីណារិទ្ធិ*

*តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 4.9 | 3.4 | 3.0 | 4.6 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 14.9 | 6.1 | 6.4 | - |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 3.6 | 3.1 | 2.6 | 1.4 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 0.7 | 0.6 | 0.5 | 1.0 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 3.6 | 3.3 | 2.4 | 1.9 |
| វៀតណាម | -0.4 | 3.8 | 3.1 | 7.8 | 8.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.4 | 1.8 | 2.6 | 3.6 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.3 | 2.2 | 1.7 | 1.3 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.4 | 2.0 | 2.4 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 2.3 | 0.6 | -0.3 | -0.1 | 1.0 | 0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | 0.0 | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.8 | 1.9 | 1.9 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.6 | 0.3 | -0.1 | -0.1 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 3.3 | 1.9 | 2.4 | 2.7 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

*តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3916.3 | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4125 | 4111.3 | 4046.7 | 4075.4 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9311 | 8577 | 8938 | 9705 | 9134 | 9122 | 9125 | 9107 | - |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.67 | 3.62 | 3.50 | 3.43 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.58 | 1.56 | 1.53 | 1.52 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 37.7 | 36.5 | 33.9 | 32.5 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,859 | 15,994 | 16,015 | 16,077 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 7.97 | 7.86 | 7.76 | 7.68 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.78 | 7.78 | 7.81 | 7.82 |
| កូរ៉េខាងត្បូង (វ៉ុន) | 1291 | 1251 | 1192 | 1145 | 1024 | 955 | 955 | 938 | 939 | 929 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.8 | 32.8 | 32.9 | 33.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.78 | 0.78 | 0.76 | 0.74 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 116.3 | 117.8 | 119.4 | 120.8 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

*តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)*

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2006 | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 108.67 | 140.18 | 154.33 | 146.10 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 446.85 | 494.92 | 552.06 | 691.44 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 289.91 | 279.10 | 294.17 | 283.89 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 207.38 | 230.17 | 255.33 | 259.95 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 67.00 | 56.39 | 54.21 | 65.41 |
| សាំង – US Gulf Coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 42.19 | 47.70 | 52.70 | 41.02 | 41.71 | 57.93 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) – US Gulf Coast (សេន/លីត្រ) | 18.72 | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 55.66 | 46.11 | 45.61 | 53.90 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ២០០៧ គំរោងវិនិយោគតិតជាទ្រព្យសកម្មជាប់លាប់បានអនុម័ត មានចំនួនថយចុះយ៉ាងខ្លាំងធៀបនឹងត្រីមាសមុន គឺធ្លាក់ចុះ ៦២% មកត្រឹម ១៩១,៣លានដុល្លារ ។ គំរោងចំនួន ២៣ កំពុងស្នើសុំការអនុមតិ ដែលវាមានចំនួនតិចជាងត្រីមាសមុន ២ គំរោង ។ ជាទូទៅ សេវាកម្ម ជាវិស័យមួយដែលមានចំណែកធំជាងគេ នៅក្នុងតំលៃអនុមតិសរុប ។ នៅត្រីមាសទី២ វិស័យនេះ ធ្លាក់ចុះ ៥៩% មកត្រឹម ១៣៧,៩លានដុល្លារ សំរាប់ ៣គំរោង ។ ក្នុងនោះ តំលៃអនុមតិសេវាទូរគមនាគមន៍ មាន ៧០លានដុល្លារ (១ គំរោង) និង វិស័យទេសចរណ៍ មាន ៥៤,៩លានដុល្លារ (១ គំរោង) ។ ឧស្សាហកម្ម ជាវិស័យសំខាន់បន្ទាប់ នៅក្នុងគំរោងវិនិយោគសរុបបានអនុម័ត ។ នៅត្រីមាសទី២ ឧស្សាហកម្មធ្លាក់ចុះ ៦៤% មកត្រឹម ៥១,២លានដុល្លារសំរាប់ ១៩គំរោង ដែលក្នុងនោះ វិស័យកាត់ដេរ មាន ៩គំរោង និងមានតំលៃ ២៤,៣លានដុល្លារ រីធ្លាក់ចុះ ៣៤% ។ ទោះបីជា កសិកម្មផ្ដល់ការងារដល់ប្រជាជនដល់ទៅ ៨០% ប៉ុន្តែវិនិយោគនៅក្នុងវិស័យនេះ មិនត្រូវបានធ្វើការអភិវឌ្ឍន៍ទេ ។ ក្នុងចំនោម ២៣ គំរោងបានអនុម័ត មានតែ ១គំរោងប៉ុណ្ណោះដែលផ្ដោតលើកសិកម្ម រីឯកសិ-ឧស្សាហកម្ម មានតំលៃ ២,១លានដុល្លារ រីធ្លាក់ចុះ ៨៩% ធៀបនឹងត្រីមាសមុន ។ វិស័យទាំងបី ត្រូវការកម្មករបន្ថែមចំនួន ២៤.៦៧០នាក់ (ថយចុះ ៣០% ធៀបនឹងត្រីមាសមុន) ។ ឧស្សាហកម្មនឹងផ្ដល់ការងារថ្មី ៩៣% សេវាកម្ម ៦,០% និង កសិកម្ម ១,០% ។

សកម្មភាពសំណង់ជាច្រើន បានលេចជារូបរាងនៅរាជធានីភ្នំពេញ និងតំបន់ជុំវិញទីក្រុង ដើម្បីកាត់បន្ថយភាពចង្អៀតតាន់តាប់ក្នុងទីក្រុងនាពេលថ្មីៗនេះ ។ បច្ចុប្បន្ន ផ្ទះល្វែងត្រូវបានសាងសង់ច្រើនជាង ផ្ទះនិងភូមិគ្រឹះ ។ នៅត្រីមាសទី២ ២០០៧ គំរោងសាងសង់សរុបបានអនុម័តនៅភ្នំពេញ មាន ១៦០,១លានដុល្លារ រីកើន ៧៧% ធៀបនឹង ត្រីមាសទី១ ។ ការអនុមតិសាងសង់ផ្ទះនិងភូមិគ្រឹះ បានកើនពីរដង ដល់ ២២,៨លានដុល្លារ ខណៈពេលដែល សំណង់ផ្ទះល្វែង បានថយចុះ ៤២% មកត្រឹម ៣៥លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ គំរោងសាងសង់សរុបបានអនុម័តនៅភ្នំពេញ កើនឡើង ៩៥% ក្នុងនេះ សំណង់ផ្ទះល្វែងថយចុះ ៣២% រីឯសំណង់ផ្ទះនិងភូមិគ្រឹះ កើនឡើងមួយជាបួន ។

ឱនភាពពាណិជ្ជកម្មនៅកម្ពុជា មានសភាពយ៉ាប់យ៉ឺនខ្លាំង គឺកើនបីដងធៀបនឹងត្រីមាសមុន (២០៨,១លានដុល្លារ) ។ ការនាំចេញ ធ្លាក់ចុះបន្តិច រីឯការនាំចូល កើនច្រើនគួរសម ។ ការនាំចេញ ធ្លាក់ចុះរហូតចាប់ពីត្រីមាសទី៣ ២០០៦ ។ នៅត្រីមាសទី២ ២០០៧ ការនាំចេញសរុបមាន ៧០៥,០លានដុល្លារ រីធ្លាក់ចុះ ០,៤% ធៀបត្រីមាសមុន ។ ការនាំចេញឈើ ធ្លាក់ចុះ ៧,៩% មកត្រឹម ១,៩លានដុល្លារ រីឯការនាំចេញត្រី ធ្លាក់ចុះ ៣៨% មកត្រឹម ០,៤លានដុល្លារ និង ការនាំចេញកៅស៊ូ ធ្លាក់ចុះ ១៨% មកត្រឹម ៦,៩លានដុល្លារ ។ ការនាំចេញអង្ករមាន ០,២លានដុល្លារ រីធ្លាក់ចុះ ៦៩% ធៀបនឹងត្រីមាសមុន ។ ប៉ុន្តែ ការនាំចេញក្នុងវិស័យកាត់ដេរកើន ១,៦% ដល់ ៦៨៨,២លានដុល្លារ ក្នុងនោះសំលៀកបំពាក់មាន ៩៦% និង ស្បែកជើង ២,៨% នៃផលិតផលកាត់ដេរនាំចេញសរុប ។ នៅត្រីមាសទី២ ការនាំចេញផលិតផលកាត់ដេរទៅសហរដ្ឋអាមេរិកធ្លាក់ចុះ ៩,៦% មកត្រឹម ៤៥១,២លានដុល្លារ រីឯការនាំចេញទៅសហគមន៍អឺរ៉ុប កើនឡើង ៥៣% ដល់ ១៦៣,១លានដុល្លារ ។ ការនាំចេញផលិតផលកាត់ដេរមានកំណើន ៨,៨% ធៀបនឹងត្រីមាសដូចគ្នាមួយឆ្នាំមុន។

ការនាំចូលសរុបនៅត្រីមាសទី២ ២០០៧ កើន ១៦% ធៀបនឹងត្រីមាសមុន ដល់ ៩៩១,៦លានដុល្លារ ។ ការនាំចូល ម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់ កើន ២២% ដល់ ៥១,៦លានដុល្លារ ដែលក្នុងនោះថ្នាំជក់មាន ៦០% និងគ្រឿងបរិភោគ ២២% ។ ការនាំចូលស៊ីម៉ង់ត៍មានកំណើន ២៦% ដល់ ២១,៦លានដុល្លារ ស្របពេលដែលការនាំចូលដែក ធ្លាក់ចុះ ២៣% មកត្រឹម ១៣,៥លានដុល្លារ ។ ទោះជាថ្លៃសាំងជាមធ្យមនៅទីផ្សារ បានកើនដល់ ៣.៨៧៦ រៀល/លីត្រ រីកើន ៣,៥% ក៏បរិមាណសាំងនាំចូលនៅតែបន្តកើនឡើង គឺកើន ២៨% ដល់ ៦៥.៣២០តោន រីស្មើនឹង ២០,២លានដុល្លារ ។ ម៉ាស៊ូតនាំចូលមាន ១៣៤.៤៣០តោន រីកើន ១៣% ធៀបនឹងត្រីមាសមុន ហើយមានតំលៃស្មើនឹង ៣៦,៦លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ ការនាំចូលសាំង និងម៉ាស៊ូត កើន ៦៤% និង ១៧% ។

នៅត្រីមាសទី២ ២០០៧ ភ្ញៀវបទេសមកដល់ប្រទេសកម្ពុជា មានសរុប ៤២៤.៥០០នាក់ រីថយចុះ ២៣% ធៀបត្រីមាសមុន ។ ភ្ញៀវមកដល់តាមផ្លូវអាកាសធ្លាក់ចុះ ២៦% មកត្រឹម ២៧៥.៦០០នាក់ ។ ដោយឡែកភ្នំពេញទទួលបាន ៤៤% និង សៀមរាប បាន ៥៦% នៃភ្ញៀវសរុបមកដល់តាមផ្លូវអាកាស ។ ភ្ញៀវមកដល់តាមផ្លូវគោកមាន ៣៤% នៃភ្ញៀវបរទេសសរុប និង ភ្ញៀវធ្វើដំណើរតាមជើងទឹកមាន ១,៤% ។ ខេត្តសៀមរាប មានភ្ញៀវសរុប ២១៥.៦៣៤នាក់ រីថយចុះ ៤៦% ធៀបត្រីមាសមុន ។ ភ្ញៀវបរទេសមកក្នុងគោលបំណង សំរាកលំហែ មានចំនួន ៣៥.២១៦នាក់ រីធ្លាក់ចុះ ២៨% ធៀបនឹងត្រីមាសមុន រីឯភ្ញៀវមកក្នុងគោលបំណងជំនួញ កើន ១៤% ដល់ ៣៤.៨០៨នាក់ ។ កូរ៉េខាងត្បូង គឺជាប្រទេសនាំមុខគេខាងភ្ញៀវធ្វើដំណើរមកកម្ពុជា (៧៨.១០៨នាក់) ។

## ហិរញ្ញវត្ថុសាធារណៈ

ថវិការដ្ឋសំរាប់ត្រីមាសទី២ មានទិន្នន័យត្រឹមតែខែឧសភាប៉ុណ្ណោះ ។ ក្នុងអំឡុង២ខែនេះ ការប្រមូលចំណូលសរុបមាន ៦៧៦.៦ពាន់លានរៀល រីកើន ៥៣% ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ចំណូលពន្ធកើន ៦៤% ដល់ ៥៨៥.១ពាន់លានរៀល ។ ពន្ធក្នុងស្រុកមាន ៧៣% នៃចំណូលពន្ធសរុប ដែលក្នុងនោះ ២០% បានមកពី ការយកពន្ធលើប្រាក់ចំនេញ ពន្ធលើប្រាក់ចំណូល និងពន្ធលើតំលៃលើស និង ៣១% បានមកពីពន្ធលើតំលៃបន្ថែម (VAT) ។ ពន្ធលើពាណិជ្ជកម្មអន្តជាតិមាន ២៦% នៃចំណូលពន្ធសរុប ក្នុងនោះពន្ធនាំចូលមាន ២៣% និង ពន្ធនាំចេញ ៣% ។ ចំណូលមិនមែនពន្ធ ដូចជា ចំណូលពីអចលនទ្រព្យ និង ការលក់ទំនិញនិងសេវា កើន ៧,២% ដល់ ៨៧,០ពាន់លានរៀល ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ចំណូលពីអចលនទ្រព្យមាន ១០% ការលក់ទំនិញនិងសេវា ៨១% និង ចំណូលមិនមែនពន្ធផ្សេងៗទៀតមាន ៨,៥% នៃចំណូលមិនមែនពន្ធសរុប។

នៅពីរបីត្រីមាសកន្លងទៅនេះ ចំណូលក្នុងស្រុកមានការកើនឡើងជាលំដាប់ និង ចំណាយថវិកាមានការប្រែប្រួលចុះឡើង ។ នៅខែមេសា-ឧសភា ២០០៧ ចំណាយថវិកា កើន ១,៩% ដល់ ៦៨០,២ពាន់លានរៀល ធៀបនឹងអំឡុងពេលដូចគ្នា ២០០៦ ។ ចំណាយចរន្តមាន ៤៦៣,៦ពាន់លានរៀល រីកើន ១៩% ។ ក្នុងនោះ ចំណាយលើប្រាក់បៀវត្សរ៍ មាន ១៦៤,៣ពាន់លានរៀល រីកើន ១៤% និង ចំណាយមិនមែនប្រាក់បៀវត្សរ៍មានកំណើន ៨,៣% ដល់ ២៨៤,៣ ពាន់លានរៀល ។ ចំណាយមិនមែនប្រាក់បៀវត្សរ៍ រួមមាន ៣៥% លើការទិញនិងថែទាំសំភារៈការិយាល័យ ៦,៤% លើការជួលនិងជួសជុលអគារ

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

៣,៩% លើការប្រាក់នៃបំណុលពីខាងក្រៅ និង ៤២% លើឧបត្ថម្ភធននិងជំនួយសង្គម ។ ចំណាយចរន្ត រួមមាន ចំណាយមូលធន ដែលថយចុះ ២២% មកត្រឹម ២១៦,៥ពាន់លានរៀល ធៀបនឹងពេលដូចគ្នា ២00៦ ។ ចំណាយមូលធនទទួលបានមូលនិធិ ៧0% ពីប្រភពខាងក្រៅ និង ៣0% ពីប្រភពខាងក្នុង។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២ ថ្លៃទំនិញទូទៅកើន ៤,៦% ធៀបនឹងត្រីមាសដូចគ្នា ២00៦ ។ ថ្លៃម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់កើន ៧,២% ហើយថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍កើន ៤,៩% ។ ថ្លៃសំលៀកបំពាក់និងស្បែកជើងកើន ២,៨% គ្រឿងប្រើប្រាស់នៅក្នុងគេហដ្ឋាន ២,៧% ចំណាយលើផ្ទះស្នាក់នៅនិងទឹកភ្លើង ២,៦% និង តំហែទាំសុខភាព ១,៥%។ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើនឡើងដោយសារមកពីការឡើងថ្លៃប្រេងឥន្ធនៈ ។

នៅត្រីមាសទី២ ប្រាក់រៀល ឡើងថ្លៃ 0,៨% ទល់នឹងដុល្លារUS បើធៀបនឹងត្រីមាសដូចគ្នា ២00៦ ។ ប្រាក់រៀល ប្តូរបានជាមធ្យម ៤0៧៥,៤ រៀល/ដុល្លារUS ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលឡើងថ្លៃ 0,៨% ដោយប្តូរបាន ២៤,៨រៀល/១00ដុង ហើយទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃ ៩,៣% ដោយប្តូរបាន ១១៨,១ រៀល/បាត ។

## ការវិវត្តន៍រូបិយវត្ថុ

ពីខែមិថុនា ២00៦-មិថុនា ២00៧ ឥណទានក្នុងស្រុក កើន ៤៥% ដល់ ៣១៣៦,0ពាន់លានរៀល ។ ក្នុងនោះ ឥណទានរដ្ឋាភិបាល កើន ៨,៨% ដល់ ២៩៧,៦ពាន់លានរៀល និង ឥណទានឯកជន កើន ៥១% ដល់ ៤៥៣៨,៧ ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាលបន្តកើនឡើងជាលំដាប់ ដោយកើន ៥៤% ដល់ ១៧00,២ពាន់លានរៀល ។ ទន្ទឹមនឹងគ្នានេះ "បំណុលផ្សេងៗ" តំណាងអោយបំណុលធនាគារជាតិបានថយចុះ ១៨% មកត្រឹម ៣៣0៧,៨ ពាន់លានរៀល ។ នៅខែមិថុនា ២00៧ ឥណទានក្នុងស្រុក និង "បំណុលផ្សេងៗ" ធ្វើអោយឥណទានក្នុងស្រុកសុទ្ធ មានលទ្ធផលអវិជ្ជមាន រឺ -១៧១,៧ ពាន់លានរៀល ប៉ុន្តែវាមានកំណើន ៧៣% បើធៀបនឹងខែដូចគ្នា ២00៦ ។ ទ្រព្យសកម្មបរទេសសុទ្ធកើន ៣៥% ដល់ ៩0៤៧,៩ពាន់លានរៀល ។

នៅខែមិថុនា ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធ បានធ្វើឱ្យរូបិយវត្ថុទូទៅសរុប (M2) កើន ៤៧% ដល់ ៨៨៧៦,១ពាន់លានរៀល ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន ។ រូបិយវត្ថុទូទៅ M2 រួមមាន រូបិយវត្ថុ M1 និងរូបិយវត្ថុផ្សេងៗ ។ រូបិយវត្ថុ M1 មាន ១៧៤៨,៤ពាន់លានរៀល រឺកើន ១៦% ក្នុងនោះ រូបិយវត្ថុនៅក្រៅធនាគារ កើន ១៥% ដល់ ១៦៨១,៩ពាន់លានរៀល ហើយបញ្ញើចរន្តមានកំណើន ២៧% ដល់ ៦៦,៥ពាន់លានរៀល ។ ប្រាក់បញ្ញើមានកាលកំណត់និងប្រាក់បញ្ញើសន្សំបានថយចុះ ១៣% មកត្រឹម ៩៨,៥ពាន់លានរៀល ខណៈពេលដែលប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៥៩% ដល់ ៧0២៩,២ពាន់លានរៀល ហើយខ្ទង់ទាំងនេះ ជារូបិយវត្ថុផ្សេងៗ ដែលកើន ៥៧% ដល់ ៧១២៧,៧ពាន់លានរៀល ។

គិតត្រឹមខែមិថុនា ២00៧ ធនាគារជាតិនៃកម្ពុជាបានតំឡើងប្រាក់បំរុងរបស់ខ្លួនរហូតដល់ ៥១៤,៥ពាន់លានរៀល រឺកើន ២៤% ធៀបនឹងខែមិថុនា ២00៦ ។ ប្រាក់បំរុងជារូបិយវត្ថុបរទេសរបស់កម្ពុជា មានតំលៃស្មើនឹង ការនាំចូលទំនិញ ៣,៧ខែ ។

## ស្ថានភាពភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែសីហា ២00៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះចំនួន ១0ក្រុម កើន ២៣% ធៀបនឹងអំឡុងពេលដូចគ្នា ២00៦ ។ ទោះយ៉ាងនេះក្តី ប្រាក់ចំណូលរបស់កម្មករសំណង់គ្មានជំនាញ កម្មករកាត់ដេរ និងអ្នកបំរើតាមភោជនីយដ្ឋាន បានថយចុះបន្តិច ។

ប្រាក់ចំណូលសុទ្ធរបស់អ្នកលក់បន្លែតូចតាច បានកើន ៧៥% ដល់ ៩១១៦រៀល នៅខែសីហា ២00៧ ធៀបនឹងខែដូចគ្នា ២00៦ ។ តួលេខនេះគឺជាកំណើនខ្ពស់បំផុត គិតតាំងពីពេលចាប់ធ្វើអង្កេតនៅឆ្នាំ១៩៩៨ ។ ទិន្នន័យបានមកពី វិទ្យាស្ថានជាតិស្ថិតិ បង្ហាញថា ថ្លៃបន្លែស្រស់ កើន ៣៦% ខណៈពេលដែលថ្លៃទំនិញភាគច្រើន នៅភ្នំពេញបានកើនតែ ៥,២% ប៉ុណ្ណោះ ក្នុងរយៈមួយឆ្នាំដល់ខែសីហា ២00៧ ។ កំណើនថ្លៃទំនិញនេះ ក៏ធ្វើអោយមានការកើនចំណូលដល់ អ្នកលក់បន្លែតូចតាចផងដែរ ។ អ្នកលក់បន្លែតូចតាច ៩៥% ឆ្លើយថាចំណូលពួកគេអាចជួយធ្វើឱ្យជីវភាពគ្រួសារបានប្រសើរឡើង ប៉ុន្តែមិនបានច្រើនប៉ុន្មានទេ ។ ពួកគេ ២0% សន្សំប្រាក់បានមួយចំនួន និង ៨0% ផ្សេងទៀតមិនបានសន្សំប្រាក់ទាល់តែសោះ ។

នៅខែសីហា ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនដល់ ៦0៣៨ រៀល រឺកើន ៤២% ច្រើនជាងអំឡុងពេលដូចគ្នា មួយឆ្នាំមុន ។ អ្នករើសអេតចាយ ៦៦% បានរាយការណ៏ថា ចំណូលពួកគេកើនឡើង ដោយសារតែអេតចាយឡើងថ្លៃ ហើយវាជាប្រាក់ចំណូលខ្ពស់ជាងគេដែរ ចាប់តាំងពីអង្កេតបានចាប់ផ្តើម ។ អ្នករើសអេតចាយ ៧0% ជាជនចំណាកស្រុកមកពីជនបទ និង ៣0% ផ្សេងទៀតជាអ្នកនៅទីក្រុងក្បែរកន្លែងចាក់សំរាម ។ ទោះបីជាចំណូលរបស់អ្នករើសអេតចាយបានកើនឡើង ប៉ុន្តែមាន ៤៣% បានរាយការណ៏ថា គ្រួសារខ្លួនបានជំពាក់បំណុលគេ ។ នេះបានន័យថា ចំណូលពួកគេមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពគ្រួសារទេ ។ យោងតាមអង្កេត ក្មេងៗជាច្រើនបានដើរតាមឪពុកម្តាយ រឺសាច់ញាតិទៅកាយគំនរសំរាមដើម្បីបានចំណូល ជាពិសេសដើម្បីទិញសំភារៈសិក្សា ហើយចំណូលដែលនៅសល់ ពួកគេសន្សំទុកសំរាប់ក្រុមគ្រួសារ ។

បន្ទាប់ពីការធ្លាក់ចុះនៅឆ្នាំ២00៦ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប បានកើនយ៉ាងខ្លាំង ចាប់តាំងពីដើមឆ្នាំ២00៧មក ។ ប្រាក់ចំណូលបានកើន ៣៣% បើធៀបនឹងអំឡុងពេលដូចគ្នា ២00៦ ដែលកំណើននេះបណ្តាលមកពីកំរើដឹកអ្នកដំណើរមានការកើនឡើង ។ ចំពោះអ្នករត់ម៉ូតូឌុបបានផ្តល់សំភាសន៏ មាន ៧៣% ប្រាប់ថា ចំណូលពួកគេ គឺគ្រប់គ្រាន់សំរាប់តែចំណាយក្នុងគ្រួសារប៉ុណ្ណោះ ដូចនេះ ពួកគេមិនអាចសន្សំប្រាក់សំរាប់បង្កើតមុខរបរផ្សេងទៀតបានទេ ។ ផ្ទុយទៅវិញ អ្នករត់ម៉ូតូឌុប ២៧% ប្រាប់ថាអាចសន្សំប្រាក់បាន ។ អ្នករត់ម៉ូតូឌុប ៧៣% បានចំណាយពី ១0 ទៅ ១៥ដុល្លារក្នុងមួយខែ សំរាប់ជួលផ្ទះស្នាក់នៅ ក្នុងអំឡុងពេលមកធ្វើការនៅភ្នំពេញ ហើយ ២៧% ផ្សេងទៀត មានទីលំនៅក្នុងក្រុង រឺនៅជាយក្រុង ។

ពីខែសីហា ២00៦-ខែសីហា ២00៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ កើន ២៤% ដល់ ១១.៧២៣រៀល ។ កម្មករទាំងនោះ ៩៧% និយាយថា ដោយសារតែការសាង់សង់មានចំនួនកាន់តែច្រើន ពួកគេអាចរកចំណូលក្នុងចន្លោះពី ៨000រៀល ទៅ ២៥.000 រៀល/ថ្ងៃ អាស្រ័យទៅតាមបទពិសោធន៏ការងារពួកគេម្នាក់ៗ ។ បន្ទាប់ពីចំណាយទៅលើម្ហូបអាហារ កម្មករមួយចំនួន មានសល់ប្រាក់ខ្លះសំរាប់ធ្វើជា

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ដើមទុន ដើម្បីបង្កើតមុខរបរផ្សេងទៀត និងលើកកំពស់ជីវភាពគ្រួសារ ។ កម្មករសំណង់មានជំនាញភាគច្រើនធ្វើការជាមធ្យម ៧ខែ/ឆ្នាំ នៅភ្នំពេញ ហើយស្ទើរតែ ៣០ថ្ងៃ/ខែ ។ នៅអំឡុងពេលដូចគ្នា គិតចាប់ពីខែសីហា ឆ្នាំ២០០៦ ចំណូលរបស់កម្មករសំណង់គ្មានជំនាញបានថយចុះ ៧,៨% មកត្រឹម ៥៩០០រៀល ។ ការថយចុះនេះ អាចបណ្តាលមកពីការកើនចំនួនកម្មករគ្មានជំនាញធ្វើចំណាកស្រុកមកពីជនបទ ។ ពួកគេធ្វើការប្រហែល ១៥ថ្ងៃ/ខែ ហើយពួកគេត្អូញត្អែរថា មិនអាចសន្សំប្រាក់បានច្រើនទេ ដោយសារត្រូវចំណាយលើម្ហូបអាហារប្រចាំថ្ងៃ មិនតែប៉ុណ្ណោះនៅឆ្នាំនេះ ទំនិញគ្រប់មុខសុទ្ធតែឡើងថ្លៃ ។ ពួកគេភាគច្រើន មកពីបណ្តាខេត្តផ្សេងៗ ហើយ ៤២% នៅលីវ និង ៥០% មានអាយុតិចជាង ២៥ឆ្នាំ និងទទួលការសិក្សាត្រឹមកំរិតបឋមសិក្សា។

នៅខែសីហា ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូមានចំនួន ៧១២៦រៀល ដែលកើន ១៨% ធៀបនឹងខែដូចគ្នា ២០០៦ ។ ការបន្ថែមម៉ោងធ្វើការ គឺជាប្រភពដ៏សំខាន់នៃការកើនចំណូលរបស់ពួកគេ ។ អង្កេតរកឃើញថា អ្នកធាក់ស៊ីក្លូធ្វើការច្រើនជាង ១១ម៉ោង/ថ្ងៃ ។ ទោះបីជាមានកំណើនចំណូល ប៉ុន្តែអ្នកធាក់ស៊ីក្លូ ៧០% បាននិយាយថា ចំណូលនេះមិនអាចផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់ទេ ។ អ្នកធាក់ស៊ីក្លូភាគច្រើន ជាជនចំណាកស្រុកបណ្តោះអាសន្នមកពីជនបទ ហើយស្ទើរតែទាំងអស់គ្នា បានស្នាក់នៅតាមផ្ទះរបស់ម្ចាស់ស៊ីក្លូ។

បើធៀបនឹងខែសីហា ២០០៦ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរបានថយចុះ ២,៥% មកត្រឹម ៩០៣៣រៀល ទោះបីជាចំណូលចារឹកបានកើនឡើង ២,២% ។ នៅខែសីហា កម្មករកាត់ដេរ ចំណាយប្រហែល ៤០ដុល្លារ លើម្ហូបអាហារ ផ្ទះស្នាក់នៅ និងគ្រឿងសំអាង ។ ចំណាយនេះកើន ២១% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ។ កម្មករកាត់ដេរភាគច្រើន អាចសន្សំប្រាក់ជាមធ្យម ២៧ដុល្លារ/ខែ ។ ពួកគេច្រើនជាង ៩០% ជាជនមកពីតាមបណ្តាខេត្តនានាជុំវិញប្រទេស ហើយភាគច្រើនបានចូលធ្វើការនៅតាមរោងចក្រ ដោយសារមានការណែនាំពីសាច់ញាតិ រឺអ្នកជិតខាង ដែលមានបទពិសោធន៏ធ្វើការនៅរោងចក្រ ។ កម្មករកាត់ដេរទាំងនោះ បានជួលផ្ទះស្នាក់នៅជាមួយគ្នា ។ ពួកគេ ៤១% ជាសមាជិកសហជីពនៅរោងចក្រដែលពួកគេធ្វើការ ហើយ ៥៩% ផ្សេងទៀត មិនបានដឹងច្រើនអំពីសកម្មភាពរបស់សហជីពទេ ។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែបានកើនឡើង ១០% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ។ កំណើនចំណូលបណ្តាលមកពីការធ្វើចំណាកស្រុក ជាពិសេសពួកក្មេងៗចេញពីភូមិទៅទីក្រុងធ្វើជាកម្មករកាត់ដេរ ដែលជាហេតុនាំអោយខ្វះកំលាំងពលកម្មនៅតាមភូមិ ។ ម្យ៉ាងវិញទៀត អ្នកស៊ីឈ្នួលធ្វើស្រែ បាននិយាយថា ពួកគេមិនមានការងារជាប់លាប់ទេ ដូច្នេះចំណូលដែលបានមកមិនអាចទ្រទ្រង់គ្រួសារទាំងមូលឡើយ ទោះបីជាពួកគេបានជួយខ្លះៗក៏ដោយ ។ ពួកគេ ៤២% បានជំពាក់បំណុលគេ ហើយបំណុលភាគច្រើន គឺបានខ្ចីពីម្ចាស់ដីស្រែ ដោយត្រូវសងទៅគេវិញជាកំលាំងពលកម្មនៅរដូវធ្វើស្រែ។

*រៀបរៀងដោយ*
*ប៊ុន ដូរីណា និង ផាន់ ដាលីស*

---

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ ...**

ការស្រាវជ្រាវ និងការងារខាងគោលនយោបាយសំខាន់ៗរបស់វិទ្យាស្ថាន CDRI ក្នុងពេលបច្ចុប្បន្ន រួមមាន:

- ការចុះស្រាវជ្រាវឆ្លងប្រទេសរួមគ្នារបស់បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ស្តីពីចំណាកស្រុកកំលាំងពលកម្មឆ្លងកាត់ព្រំដែនក្នុងមហាអនុតំបន់មេគង្គ ដែលបង្ហាញពីការរីកចំរើនទំនាក់ទំនងក្នុងបណ្តាញនៅក្នុងតំបន់នេះ ហើយនិងគំរោងបណ្តាញវិភាគអភិវឌ្ឍន៍ DAN ដែលផ្តោតលើពាណិជ្ជកម្មផលិតផលកសិកម្ម នៅក្នុងមហាអនុតំបន់មេគង្គ ។
- ការសិក្សាពីការដឹកនាំខាងនយោបាយនៅតាមមូលដ្ឋាន ដែលជាប់ទាក់ទងនឹងគោលដៅកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការវិភាគលើ ច្បាប់រៀបចំអង្គការស្តីពីអភិបាលកិច្ចថ្នាក់ក្រោមជាតិនៅកម្ពុជា ។
- ការសិក្សាលើអភិបាលកិច្ចធនធានទឹកសំដៅកាត់បន្ថយភាពក្រីក្រ ដែលជាផ្នែកមួយ នៃកម្មវិធីកសាងសមត្ថភាពស្រាវជ្រាវលើធនធានទឹករយៈ ៥ឆ្នាំ របស់វិទ្យាស្ថាន CDRI ដើម្បីកំណត់ពីរបៀបរៀបចំខាងអភិបាលកិច្ចធនធានទឹក ដែលអាចជួយជំរុញផលិតកម្មកសិកម្មអោយមានចីរភាព និងទទួលបានទឹកសំរាប់ចែកចាយប្រើប្រាស់ស្មើភាពគ្នា ។
- ការវិភាគចំណាយនិងផលចំណេញ នៃការអភិវឌ្ឍន៍ចំការកៅស៊ូនៅកម្ពុជា ដោយពិនិត្យពីការដោះដូរផលចំណេញចុះឡើងក្នុងការអភិវឌ្ឍន៍ចំការកៅស៊ូ ។
- គំរោងរួមគ្នាមួយស្តីពី ព្រៃតំបន់ត្រូពិកសំរាប់ការកាត់បន្ថយភាពក្រីក្រ ដែលមានតាំងពីទិន្នន័យតាមគ្រួសារ រហូតដល់ការវិភាគសរុបសំរាប់ ៥ប្រទេស ដើម្បីបង្កើនការយល់ដឹងពីតួនាទីរបស់ព្រៃតំបន់ត្រូពិកក្នុងការទប់ស្កាត់ និងកាត់បន្ថយភាពក្រីក្រនៅជនបទ ។
- ការសិក្សាពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើបរិស្ថាន នៅក្នុងមហាអនុតំបន់មេគង្គ ដែលបានចុះកិច្ចសន្យាប្រគល់អោយធ្វើដោយបណ្តាញចំនេះដឹងពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ។
- អង្កេតលើបរិស្ថានធម្មជាតិ និងសង្គម ធ្វើឡើងដោយវិទ្យាស្ថាន CDRI ក្នុងកិច្ចសហការជាដៃគូជាមួយ ក្រុមសិក្សារបស់ JICA ដើម្បីវាយតំលៃពីបញ្ហាខាងបរិស្ថានធម្មជាតិនិងសង្គម ជួយដល់ការសិក្សាបួងមេ សំរាប់ការអភិវឌ្ឍន៍វារីអគ្គិសនីនៅកម្ពុជា ។

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 | 2.1 |
| ឧស្សាហកម្ម | 109.4 | 105.2 | 67.7 | 137.2 | 187.9 | 914.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 | 51.2 |
| កាត់ដេរ | *81.5* | *26.5* | *27.2* | *68.1* | *132.6* | *174.4* | *30.5* | *9.6* | *23.2* | *26.1* | *36.6* | *24.3* |
| សេវាកម្ម | 150.1 | 118.4 | 145.3 | 168.4 | 91.8 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 | 138.0 |
| សណ្ឋាគារ និងទេសចរណ៍ | *79.8* | *73.8* | *47.1* | *124.1* | *55.9* | *102.6* | *0.0* | *26.2* | *3.5* | *315.3* | *140.3* | *55.0* |
| សរុប | 269.2 | 224.0 | 253.3 | 309.3 | 292.0 | 1096.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 | 191.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 | -61.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -40.0 | -16.8 | 13.1 | 22.1 | -5.6 | 275.6 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 | 91.8 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 10.9 | 22.8 |
| ផ្ទះល្វែង | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 59.9 | 35.0 |
| ផ្សេងៗ | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 19.5 | 102.2 |
| សរុប | 205.4 | 196.3 | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 90.4 | 160.1 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 15.6 | 77.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -37.2 | -4.4 | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 34.2 | 94.6 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 2352.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 | 705.0 |
| រួមមានៈ សំលៀកបំពាក់ | 962.1 | 1202.2 | 1355.8 | 1628.4 | 2027 | 2253.3 | 568.5 | 632.4 | 782.0 | 716.0 | 677.5 | 688.2 |
| - ទៅសហរដ្ឋអាមេរិក | *714.1* | *840.9* | *943.4* | *1099.8* | *1270.9* | *1546.1* | *402.5* | *438.6* | *522.8* | *483.2* | *499.1* | *451.2* |
| - ទៅសហគមន៍អ៊ឺរ៉ុប | *228.1* | *323.3* | *356.3* | *414.7* | *590.8* | *503.1* | *110.6* | *142.2* | *188.1* | *160.1* | *106.3* | *163.1* |
| - ប្រទេសផ្សេងទៀត | *19.9* | *38.0* | *56.1* | *113.8* | *165.3* | *204.1* | *55.3* | *51.6* | *71.0* | *72.8* | *72.0* | *73.8* |
| កសិកម្ម | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 99.5 | 34.7 | 20.2 | 25.5 | 20.7 | 30.3 | 16.8 |
| - កៅស៊ូ | *29.6* | *25.9* | *29.7* | *35.1* | *38.3* | 36.7 | 7.8 | 9.8 | 13.6 | 10.2 | 8.4 | 6.9 |
| - ឈើ | *32.9* | *22.3* | *16.0* | *10.2* | *11.1* | 10.3 | 2.1 | 2.3 | 2.5 | 1.7 | 2.1 | 2.0 |
| - ត្រី | *5.4* | *6.0* | *4.3* | *2.8* | *10.6* | 10.1 | 1.9 | 1.0 | 1.6 | 1.4 | 0.7 | 0.4 |
| - ផ្សេងៗ | *26.2* | *11.8* | *47.4* | *31.6* | *21.3* | 42.6 | 22.9 | 7.0 | 7.7 | 7.5 | 19.0 | 7.5 |
| ការនាំចូលសរុប | 1417.7 | 1501.4 | 1707.8 | 1824.9 | 2149.0 | 2513 | 690.7 | 774.9 | 784.3 | 807.1 | 790.9 | 911.6 |
| រួមមានៈ - សាំង | - | - | 25.9 | 33.2 | 30.2 | 40.2 | 10.9 | 12.4 | 13.1 | 13.2 | 15.7 | 20.2 |
| - ម៉ាស៊ូត | - | - | 100.8 | 109.6 | 109.4 | 93.1 | 32.5 | 32.2 | 30.1 | 27.2 | 31.9 | 36.6 |
| - សំភារៈសំណង់ | - | - | 12.9 | 80.8 | 95.3 | 134.7 | 37.0 | 39.1 | 42.5 | 35.8 | 44.1 | 47.3 |
| - ផ្សេងៗ | - | - | 1568.2 | 1601.3 | 1914.0 | 2245 | 610.3 | 691.2 | 698.5 | 731.0 | 699.2 | 807.5 |
| ជញ្ជីងពាណិជ្ជកម្ម | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -160.1 | -87.5 | -122.4 | 23.2 | -70.4 | -83.1 | -208.1 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | -5.4 | 11.2 | 23.7 | -8.4 | -5.4 | 1.6 |
| ការនាំចេញសរុប | - | - | - | - | - | - | -6.4 | 8.2 | 23.7 | -8.8 | -3.9 | 0.4 |
| ការនាំចូលសរុប | - | - | - | - | - | - | -0.03 | 12.2 | -1.6 | 5.9 | -2.0 | 15.5 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 11.2 | 27.8 | 27.1 | 10.2 | 19.1 | 19.2 | 8.8 |
| ការនាំចេញសរុប | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 11.6 | 30.3 | 26.7 | 10.6 | 14.3 | 17.3 | 8.0 |
| ការនាំចូលសរុប | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 16.9 | 32.6 | 15.6 | 20.9 | 16.8 | 14.5 | 17.8 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 | 275.6 |
| តាមផ្លូវគោក និងទឹក | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 | 148.9 |
| សរុប | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 | 424.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 | -22.9 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 | 19.2 |

*Source: Ministry of Tourism.*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២០០៦ (ពាន់លានរៀល)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1* | Q2* | Q3* | Q4* | 2007 Q1* | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1528 | 1530 | 1744 | 1764 | 2126 | 2625 | 595.9 | 731.5 | 732.2 | 1199.6 | 824.9 | 676.6 |
| ចំណូលចរន្ត | - | 1521 | 1728 | 1733 | 2107 | 2474 | 593.2 | 726.9 | 716.8 | 844.9 | 824.9 | 676.6 |
| ចំណូលពន្ធ | 1096 | 1096 | 1227 | 1220 | 1577 | 1911 | 484.7 | 558.6 | 565.8 | 661.8 | 699.9 | 585.1 |
| ពន្ធគយ | 376 | 376 | 424 | 395 | 513 | 573 | 135.5 | 151.7 | 157.2 | 200.0 | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | - | - | - | 487.9 | 429.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | - | - | 212.1 | 155.5 |
| ចំណូលមិនមែនពន្ធ | 424 | 424 | 501 | 513 | 530 | 563 | 108.5 | 168.3 | 151.0 | 183.1 | 125.0 | 87.0 |
| អាជីវកម្មព្រៃឈើ | 28 | 29 | 15 | 7 | 2 | 3 | 0.5 | 0.7 | 0.3 | 0.9 | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 124 | 122 | 123 | 120 | 94 | 123 | 11.4 | 30.0 | 11.7 | 30.0 | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | - | - | - | 27.9 | 8.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | - | - | 88.8 | 70.7 |
| ចំណូលជាមូលធន | 8 | 9 | 16 | 31 | 19 | 152 | 2.7 | 4.6 | 15.4 | 354.7 | 0.0 | 0.0 |
| ចំណាយសរុប | 2332 | 2332 | 2948 | 2757 | 2932 | 3295 | 932.1 | 1020.1 | 1030.6 | 1191.9 | 923.9 | 680.2 |
| ចំណាយជាមូលធន | 976 | 977 | 1388 | 1171 | 1163 | 1328 | 390.5 | 394.7 | 423.8 | 429.1 | 367.1 | 216.5 |
| ចំណាយចរន្ត | 1356 | 1355 | 1560 | 1586 | 1769 | 1967 | 541.7 | 625.4 | 606.9 | 762.8 | 556.8 | 463.7 |
| អប់រំ និងសុខាភិបាល | 344 | 343 | 454 | 473 | 518 | 351 | 80.3 | 202.3 | 150.1 | 281.3 | - | - |
| ការពារ និងសន្តិសុខជាតិ | 404 | 405 | 438 | 411 | 423 | 451 | 78.1 | 116.7 | 155.3 | 170.1 | - | - |
| ក្រសួងផ្សេងៗទៀត | 636 | 637 | 668 | 702 | 828 | 1165 | 383.2 | 306.4 | 301.5 | 311.4 | - | - |
| បៀវត្សរ៍ | 517 | 509 | 587 | 615 | 640 | 711 | 140.5 | 210.3 | 230.6 | 240.6 | 199.7 | 164.3 |
| ឧបត្ថម្ភធន និង ជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | - | - | 61.9 | 119.3 |
| ឱនភាពជាទូទៅ | -804 | -802 | -1204 | -993 | -806 | -706 | -336.3 | -288.5 | -298.5 | 7.7 | -99.0 | -3.6 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 768 | 766 | 1249 | 886 | 864 | 1127 | 308.0 | 341.3 | 335.2 | 376.2 | 344.0 | 160.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 36 | 37 | -45 | 106 | 148 | -396 | 28.3 | -52.8 | -36.7 | -383.9 | -245.0 | 156.9 |

Provisional for 2007. Q2 up to May. *Revised. Source: MEF web site.

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៩-២០០៧

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 16.4 | 15.8 | 12.0 | 8.5 | 7.2 | 4.2 | 4.6 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 5.8 | 6.1 | 4.5 | 4.9 | 3.4 | 3.0 | 4.6 |
| - ម្ហូបអាហារ | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 8.6 | 10.6 | 6.3 | 5.8 | 3.3 | 3.0 | 7.2 |
| - ដឹកជញ្ជូន | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 11.4 | 9.7 | 10.0 | 10.1 | 6.8 | 5.2 | 5.0 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4119.7 | 4,094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 | 4075.4 |
| រៀលក្នុង ១ បាតថៃ* | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 | 118.0 |
| រៀលក្នុង ១០០ ដុងវៀតណាម* | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 | 24.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 | 79.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1105 | 1329 | 1521 | 1508 | 2088 | 2633 | 2,867 | 3110 | 3333 | 3250 | 3067 | 3100 |
| ថ្លៃសាំង (រៀល/លីត្រ) | 1760 | 2113 | 2084 | 2150 | 2833 | 3442 | 3,767 | 4000 | 4200 | 4050 | 3750 | 3900 |

Sources: CDRI, IMF, NIS, Ministry of Economy and Finance

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៩-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 2589 | 3080 | 3737 | 4027 | 4797 | 5475 | 6,410 | 6682 | 6958 | 7224 | 8056 | 9048 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -759 | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 | -172 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 3 | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 | -1403 |
| ឥណទានដល់ផ្នែកឯកជន | 898 | 936 | 1059 | 1337 | 1817 | 2394 | 2,778 | 2997 | 3288 | 3628 | 4066 | 4537 |
| រូបិយវត្ថុទូទៅ M2 | 1830 | 2204 | 2888 | 3329 | 4330 | 5025 | 5,711 | 6045 | 6461 | 6942 | 7793 | 8876 |
| រូបិយវត្ថុ M1 | 540 | 609 | 813 | 937 | 1153 | 1323 | 1,449 | 1512 | 1563 | 1658 | 1794 | 1748 |
| រូបិយវត្ថុផ្សេងៗ | 1290 | 1595 | 2075 | 2392 | 3177 | 3702 | 4,262 | 4533 | 4898 | 5285 | 5999 | 7128 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 26.8 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 | 46.8 |
| រូបិយវត្ថុ M1 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 | 15.7 |
| រូបិយវត្ថុផ្សេងៗ | 41.4 | 23.6 | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 វិច្ឆិកា | 2003 | 2004 | 2005 | 2006 សីហា | វិច្ឆិកា | 2007 កុម្ភៈ | ឧសភា | សីហា | 2007 កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 6063 | 7393 | 6534 | 9245 | 7126 | -17 | 8 | 18 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 5238 | 7045 | 6010 | 9798 | 7704 | -8 | 33 | 47 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 5197 | 6125 | 6125 | 8951 | 9116 | -1 | 38 | 75 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 4266 | 3903 | 4530 | 5533 | 6038 | -9 | 23 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4292 | 4498 | 4078 | 5150 | 4193 | -13 | 21 | -2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4137 | 4653 | 4126 | 4531 | 4561 | 0 | 0 | 10 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 9264 | 8957 | 11146 | 8347 | 9033 | 21 | 6 | -2 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 6744 | 8386 | 9144 | 12,886 | 8979 | 3 | 47 | 33 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6407 | 6028 | 5263 | 6075 | 5901 | -15 | -5 | -2 |
| កម្មករសំណង់មានជំនាញ | 13127 | 13111 | 12679 | 10316 | 9833 | 9466 | 10215 | 11,892 | 11,723 | -14 | 21 | 24 |

* Waitresses' earnings do not include meals and accommodation provided by shop owners.

Surveys on the revenue of waitresses, rice-field workers, unskilled workers, motorcycle taxi and construction workers began in February 2000. Source: CDRI

# ព័ត៌មានថ្មីៗ ពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

នៅខែតុលា ២០០៧ នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានចូលរួមវេទិកាប្រចាំឆ្នាំលើកទី៣ នៃវិទ្យាស្ថាននៅអាស៊ីខាងកើត ដែលរៀបចំឡើងនៅទីក្រុងសេអ៊ូលដោយ វិទ្យាស្ថានកូរ៉េសំរាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ ។ វេទិកាឆ្នាំនេះពិភាក្សាអំពី "សមាហរណកម្មសេដ្ឋកិច្ចនៅអាស៊ីខាងកើតៈ ការអភិវឌ្ឍន៍ថ្មីៗ និង របៀបវារៈសំខាន់ៗ" ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃ វិទ្យាស្ថានស្រាវជ្រាវឈានមុខខាងគោលនយោបាយរបស់បណ្តាប្រទេសអាស៊ាន ចិន កូរ៉េ និងជប៉ុន ។ វេទិកាបានពិភាក្សាលើបញ្ហានានាខាងពាណិជ្ជកម្មនិងវិនិយោគ សហប្រតិបត្តិការអភិវឌ្ឍន៍ និង ហិរញ្ញវត្ថុដែលមានសារៈសំខាន់បំផុតសំរាប់សមាហរណកម្មសេដ្ឋកិច្ច និងលទ្ធភាពកសាងសហគមន៍អាស៊ីខាងកើតនាពេលអនាគត ។

នៅខែវិច្ឆិកា វបសអ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសន្និសីទឆ្នាំ២០០៧ ស្តីពី ការវិនិយោគ ការធ្វើពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា ព្រមទាំង កិច្ចប្រជុំតុមូលពាណិជ្ជកម្មលើកទី៥ ជាមួយរាជរដ្ឋាភិបាល ក្រោមប្រធានបទ "ប្រទេសកម្ពុជាៈ ទីកន្លែងល្អ ពេលវេលាល្អសំរាប់វិនិយោគល្អ"។ វបសអ បានផ្តល់វាគ្មិនជំនាញចូលរួមក្នុងបួនវគ្គ គឺទស្សនវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មសំរាប់ប្រទេសកម្ពុជា, ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ, ផលិតកម្ម ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូចនិងខ្នាតមធ្យម និង កសិ-ឧស្សាហកម្ម, វិស័យទេសចរណ៍ សណ្ឋាគារ និងសេវាធ្វើដំណើរ ។ សន្និសីទនេះបានទាក់ទាញ អ្នកចូលរួមមកពីវិស័យឯកជន និងជាអ្នកវិនិយោគទុន ចំនួនប្រមាណ ៦០០នាក់ មកពីក្នុងស្រុក តំបន់ និងអន្តរជាតិ ។

នាពេលបច្ចុប្បន្ន ការងាររៀបចំបានដំណើរការយ៉ាងល្អសំរាប់ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨ ដែលជាកម្មវិធីរួមសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និងធនាគារ អេអិនហ្សិត រ៉ូយ៉ាល់ ។ សន្និសីទនឹងប្រារព្ធធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ ក្រោមប្រធានបទ "ការកេណ្ឌប្រមូលធនធាននៅកម្ពុជា -ធនធានមនុស្ស ធម្មជាតិ ហិរញ្ញវត្ថុ- សំរាប់ការអភិវឌ្ឍន៍ ការរីកលូតលាស់ និងវិបុលភាពប្រកបដោយគុណភាព" ។ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទចក្ខុវិស័យលើកទី២នេះទៀត ហើយវិទ្យាស្ថាន CDRI នឹងធ្វើការចេញផ្សាយនូវរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-០៨ របស់ខ្លួន ។

## ផ្នែកស្រាវជ្រាវ

វិទ្យាស្ថាន CDRI បានរៀបចំសិក្ខាសាលាជាច្រើនដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវនៅត្រីមាសទី៤ ឆ្នាំ២០០៧នេះ ដូចជា នៅខែតុលា សិក្ខាសាលាស្តីពីការចុះបញ្ជីដីធ្លី ដោយរួមសហការជាមួយក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីផ្សព្វផ្សាយលទ្ធផលនៃការសិក្សាជាមូលដ្ឋានលើការចុះបញ្ជីដីធ្លីនៅតាមតំបន់ជនបទ និងទីក្រុង, នៅខែវិច្ឆិកា សិក្ខាសាលាស្តីពី លទ្ធផលសំរេចនៃការសិក្សាចំបងៗរបស់វិទ្យាស្ថាន CDRI ស្តីពីភាពក្រីក្រដែលរួមមាន ការសិក្សាពីការចាកផុតពីភាពក្រីក្រ ការវាយតំលៃពីភាពក្រីក្រដោយមានការចូលរួមនៅតំបន់ទន្លេសាប និងផលប៉ះពាល់នៃសមាហរណកម្មក្នុងតំបន់ទៅលើភាពក្រីក្រ ។ នៅខែធ្នូ មានធ្វើសិក្ខាសាលាបច្ចេសទេសរយៈពេលពីរថ្ងៃ ស្តីពីការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ដើម្បីជាជំនួយដល់វិទ្យាស្ថាន CDRI ក្នុងការរចនាតាក់តែងកម្មវិធីស្រាវជ្រាវរយៈ ៥ឆ្នាំ លើឌីណាមិកនៃភាពក្រីក្រ ហើយនិងសិក្ខាសាលាស្តីពីការធ្វើចំណាកស្រុកក្នុងប្រទេសពីជនបទមកទីក្រុងរបស់យុវជន ដើម្បីផ្សព្វផ្សាយលទ្ធផលនៃការសិក្សារយៈ១ឆ្នាំ ដែលបានទទួលមូលនិធិពី UNFPA ។

*តទៅទំព័រទី ១៧*

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១១ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០០៧

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh

ISBN: 99950 –52-06-7

គ្រឹះស្ថានផ្សាយៈ វបសអ

គ្រប់គ្រងកែសំរួលៈ យូ សិទ្ធីរិទ្ធ

កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា

ជំនួយការកែសំរួលៈ យេន សុផានី និង គឹម ចិត្រា

រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព CDRI

© រក្សាសិទ្ធិ ២០០៧ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។